ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន
# ២០២៣-២០២៨

ដើម្បី ភាពស្អាត ភាពបៃតង និងចីរភាព

១៨ វិច្ឆិកា ២០២៣

# យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន
# ២០២៣-២០២៨

អាសយដ្ឋាន៖ អគារមរតកតេជោ ដីឡូតិ៍លេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ

# អារម្ភកថា

ក្រោមម្លប់សុខសន្តិភាព ឯកភាពជាតិ និងឯកភាពទឹកដីទាំងស្រុង ដែលបានកើតចេញឡើងពីធន្ទះដ៏មោះមុត មនសិការស្នេហាជាតិដ៏ស្មោះស្ម័គ្រ ការបូជាសាច់ស្រស់ឈាមស្រស់ ការធ្វើពលិកម្មគ្រប់បែបយ៉ាង និងការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** តាមរយៈ នយោបាយឈ្នះ-ឈ្នះ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តប្រកបដោយជោគជ័យនូវ**យុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណ ទាំង៤ដំណាក់កាល** ដោយសម្រេចបាននូវសមិទ្ធផលធំៗលើគ្រប់វិស័យ ទាំងកិច្ចការនយោបាយ សង្គម និងសេដ្ឋកិច្ច ដែលនាំឱ្យប្រទេសកម្ពុជាមានការអភិវឌ្ឍ គួរជាទីមោទនៈបំផុត។

ជារួម **យុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណ ទាំង៤ដំណាក់កាល** បានបំពេញតួនាទីយ៉ាងល្អប្រសើរ នូវរបៀបវារៈគោលនយោបាយអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ដែលផ្តល់នូវក្របខ័ណ្ឌយុទ្ធសាស្ត្ររួម សម្រាប់ការកសាងស្ថាប័នរដ្ឋមួយដ៏រឹងមាំនិងមានឯករាជ្យ។ ប្រព័ន្ធអភិបាលកិច្ចក៏ត្រូវបានធ្វើទំនើបកម្មជាបន្តបន្ទាប់ប្រកបដោយប្រសិទ្ធភាព និងបានជំរុញការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចក្នុងល្បឿនលឿន ប្រែក្លាយកម្ពុជាឱ្យក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងរយៈពេលដ៏ខ្លីជាមួយនឹងកំណើនសេដ្ឋកិច្ចខ្ពស់ ការកាត់បន្ថយភាពក្រីក្រយ៉ាងឆាប់រហ័ស និងការធ្វើសមាហរណកម្មប្រកបដោយជោគជ័យទៅក្នុងតំបន់និងសកលលោក។ ក្នុងរយៈពេល៣០ឆ្នាំកន្លងមក ចាប់តាំងពីការបង្កើតស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាននៅឆ្នាំ១៩៩៣ វិស័យបរិស្ថានត្រូវបានទទួលការគាំទ្រ យ៉ាងពេញទំហឹងពីរាជរដ្ឋាភិបាល ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធពីក្រសួង-ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ព្រមទាំងការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋ លើការគ្រប់គ្រងបរិស្ថាននិងធនធានធម្មជាតិ។ លើសពីនេះទៀត ការបំពេញតួនាទីយ៉ាងយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់លំដាប់ថ្នាក់ក្រោមឱវាទក្រសួងបរិស្ថាន បានធ្វើឱ្យការអនុវត្តគោលនយោបាយ

យុទ្ធសាស្ត្រ ផែនការ និងលិខិតបទដ្ឋានគតិយុត្ត ទទួលបាននូវលទ្ធផលគួរជាទីពេញចិត្ត។

ឈរលើមូលដ្ឋាននៃសមិទ្ធផល ដែលសម្រេចបានក្នុងរយៈពេល២៥ឆ្នាំកន្លងមក ក្នុងក្របខណ្ឌនៃការអនុវត្តយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំង៤ដំណាក់កាល រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវ «**យុទ្ធសាស្ត្របញ្ចកោណ**» ដំណាក់កាលទី១ ដើម្បីកំណើនសេដ្ឋកិច្ច បង្កើតការងារ ធានាសមធម៌ បង្កើនប្រសិទ្ធភាព និងរក្សាចីរភាព សំដៅឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជន ឈានឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ **យុទ្ធសាស្ត្របញ្ចកោណ** គឺជាយុទ្ធ-សាស្ត្រសម្លឹងទៅមុខក្នុងរយៈពេល២៥ឆ្នាំ ដោយបានគិតគូរនិងដាក់ចេញជា៥ដំណាក់កាល ដើម្បីតម្រង់ទិសអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនៃនីតិកាលនីមួយៗនៃរដ្ឋសភា។

អនុលោមតាម «**យុទ្ធសាស្ត្របញ្ចកោណ**» **ដំណាក់កាលទី១** និងឈរលើមូលដ្ឋាននៃគោលនយោបាយ និងយុទ្ធសាស្ត្រជាតិដែលមានជាធរមាន ព្រមទាំងក្របខណ្ឌអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ ក្រសួងបរិស្ថានបានរៀបចំ «**យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន**» **ឆ្នាំ២០២៣-២០២៨** ក្នុងគោលបំណងតម្រង់ទិស និងចង្អុលបង្ហាញការងារជាអាទិភាព ដើម្បីធានាឱ្យបាននូវចីរភាពបរិស្ថាន និងសុក្រឹតកម្មបរិស្ថានកិច្ច ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងលើកកម្ពស់សេដ្ឋកិច្ចបៃតង សំដៅសម្រេចគោលដៅយុទ្ធសាស្ត្របញ្ចកោណ គឺ «**ជាប្រទេសអព្យាក្រឹតកាបូន និងមានគម្របព្រៃឈើ៦០ភាគរយ នៅឆ្នាំ២០៥០**»។

**យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន** បានរចនាឡើងជារូបរង្វង់ ដោយមាន **យុទ្ធសាស្ត្រស្នូល** ផ្តោតលើមុំចំនួន៣ មានជាអាទិ៍ ការពង្រឹងគោលនយោបាយការកសាងរដ្ឋបាលឌីជីថល និងពង្រីកការផ្សព្វផ្សាយ ដែលមុំទាំងបីនេះ ជាកម្លាំងចលករដ៏សំខាន់ក្នុងការរុញបង្វិលយុទ្ធសាស្ត្របីផ្សេងទៀត ឱ្យដំណើរការដោយ

ជោគជ័យ គឺ **យុទ្ធសាស្ត្រទី១ ភាពស្អាត** ដែលផ្តោតលើមុំ ការត្រួតពិនិត្យការបំពុល ការធ្វើទំនើបកម្មប្រព័ន្ធវិនិច្ឆ័យការបំពុល និងការលើកកម្ពស់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន **យុទ្ធសាស្ត្រទី២ ភាពបៃតង** ផ្តោតលើមុំ ការពង្រីកចលនាដាំដើមឈើ ការជំរុញការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងការលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន និង**យុទ្ធសាស្ត្រទី៣ ចីរភាព** ផ្តោតលើមុំ ការអនុវត្តអនុលោមភាព ការពង្រីកកិច្ចសហប្រតិបត្តិការ និងការពង្រឹងការសម្របសម្រួល។

ក្នុងនាមក្រសួងបរិស្ថាន ខ្ញុំបាទសូមគោរពថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានផ្តល់ការណែនាំដល់ការរៀបចំ និងអនុញ្ញាតដ៏ខ្ពង់ខ្ពស់ឱ្យក្រសួងបរិស្ថានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ «យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ២០២៣-២០២៨» តាមរយៈលិខិតលេខ១១៧០ សជណ.ដប ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។ ខ្ញុំមានជំនឿយ៉ាងមុតមាំថា អង្គភាពក្រោមឱវាទក្រសួងនឹងរួមសាមគ្គីគ្នា ព្រមទាំងសហការជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ក្នុងការអនុវត្ត **«យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ឆ្នាំ២០២៣-២០២៨»** ប្រកបដោយជោគជ័យ ដើម្បីជាឧត្តមប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់ជំនាន់ និងលើកតម្កើងកិត្យានុភាពប្រទេសកម្ពុជា លើឆាកអន្តរជាតិ៕

ថ្ងៃពុធ ៣កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**

**បណ្ឌិត អ៊ាង សុផល្លែត**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ :** ១១៧០.សជណ.ជប

ក្រសួងបរិស្ថាន
បញ្ជូល លេខ 10277 ថ្ងៃទី 7 ខែ 11 ឆ្នាំ២០23 ម៉ោង 4:00

ថ្ងៃ ចន្ទ ៨ រោច ខែ អស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ជម្រាបជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**កម្មវត្ថុ៖** ករណីសំណើសុំគោលការណ៍អនុញ្ញាតដ៏ខ្ពង់ខ្ពស់ ដើម្បីប្រកាសដាក់ឱ្យប្រើប្រាស់ **«យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន» ឆ្នាំ២០២៣-២០២៨។**

**យោង** ៖- លិខិតលេខ១៩១១ សណ ប.ស្ត ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ របស់ក្រសួងបរិស្ថាន

- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលអនុញ្ញាតជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន ប្រកាសដាក់ឱ្យប្រើប្រាស់ **«យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន» ឆ្នាំ២០២៣-២០២៨។**

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**សួង សុភ័ណ្ឌ**

**ចម្លងជូន៖**

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ឯកសារ កាលប្បវត្តិ

# មាតិកា


ទំព័រ

**១. សេចក្តីផ្តើម** ១

**២. ចក្ខុវិស័យ** ៣

**៣. បេសកកម្ម** ៣

**៤. គោលដៅជាយុទ្ធសាស្ត្រ** ៣

**៤.១. យុទ្ធសាស្ត្រស្នូល** ៤

មុំទី១ ការពង្រឹងគោលនយោបាយ ៤

មុំទី២ ការកសាងរដ្ឋបាលឌីជីថល ៨

មុំទី៣ ការពង្រីកការផ្សព្វផ្សាយ ១០

**៤.២. យុទ្ធសាស្ត្រទី១ ភាពស្អាត** ១៤

មុំទី១ ការត្រួតពិនិត្យការបំពុល ១៤

មុំទី២ ការធ្វើទំនើបកម្មប្រព័ន្ធវិនិច្ឆ័យការបំពុល ១៧

មុំទី៣ ការលើកកម្ពស់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ២០

**៤.៣. យុទ្ធសាស្ត្រទី២ ភាពបៃតង** ២២

មុំទី១ ការពង្រីកចលនាដាំដើមឈើ ២២

មុំទី២ ការជំរុញការគ្រប់គ្រងតំបន់ការពារធម្មជាតិ ២៤

មុំទី៣ ការលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន ២៦

**៤.៤. យុទ្ធសាស្ត្រទី៣ ចីរភាព** ២៩

មុំទី១ ការអនុវត្តអនុលោមភាព ២៩

មុំទី២ ការពង្រីកកិច្ចសហប្រតិបត្តិការ ៣៣

មុំទី៣ ពង្រឹងការសម្របសម្រួល ៣៦

**៥. យន្តការអនុវត្ត** ៣៨

**៥.១. យន្តការអន្តរក្រសួង** ៣៩

**៥.២. យន្តការក្រសួង** ៤១

**៥.៤. យន្តការថ្នាក់ក្រោមជាតិ** ៤២

**៦. សន្និដ្ឋាន** ៤៣

## ១. សេចក្តីផ្តើម

បរិស្ថាន គឺជាសសរស្តម្ភដ៏សំខាន់មួយ ក្នុងចំណោមសសរស្តម្ភទាំងបួន (បរិស្ថាន សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌) ដែលជាអ្នកទ្រទ្រង់ដល់ការអភិវឌ្ឍប្រកបដោយចីរភាព។ ក្នុងរយៈពេលជាងពីរទសវត្សរ៍ មុនវិបត្តិជំងឺកូវីដ១៩ ប្រទេសកម្ពុជាបានសម្រេចនូវកំណើនសេដ្ឋកិច្ចខ្ពស់គួរកត់សម្គាល់ ជាមធ្យមក្នុងរង្វង់៧ភាគរយ និងបានរក្សានូវលំនឹងម៉ាក្រូសេដ្ឋកិច្ច ធានាដល់បរិវត្តកម្ម និងពិពិធកម្មនៃសេដ្ឋកិច្ចជាតិ។ ស្របពេលដែលប្រទេសកម្ពុជា សម្រេចបាននូវកំណើនសេដ្ឋកិច្ចដ៏ល្អប្រសើរ ក្រសួងបរិស្ថានកម្ពុជាក៏មានលទ្ធភាពបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបានយ៉ាងប្រសើរផងដែរ លើទិដ្ឋភាពសំខាន់ៗចំនួនបួន រួមមាន (១) ការកសាងរដ្ឋបាលទំនើប (២) ការអភិរក្សជីវៈចម្រុះនិងការគ្រប់គ្រងធនធានធម្មជាតិ (៣) ការអភិវឌ្ឍសហគមន៍មូលដ្ឋាន និង(៤) ការលើកកម្ពស់ការរស់នៅប្រកបដោយចីរភាព។

**យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន (២០២៣-២០២៨)** ត្រូវបានរៀបចំឡើងដោយអនុលោមតាម កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ឆ្នាំ២០២៣-២០២៨នៃរាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ដែលបានគូសបញ្ជាក់ឡើងវិញពីបេសកកម្ម និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងវិស័យបរិស្ថាន ដើម្បីឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋទូទៅ សំដៅឈានឆ្ពោះទៅកាន់ការអភិវឌ្ឍប្រកបដោយចីរភាព។ ស្របពេលដែលការគ្រប់គ្រងវិស័យបរិស្ថាន និងធនធានធម្មជាតិ ត្រូវបានធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់ ជាពិសេសវិស័យដីធ្លី ទឹក ធនធានរ៉ែ និងព្រៃឈើ កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការអនុវត្តការងារអាទិភាពសម្រាប់វិស័យនេះ គឺជាការចាំបាច់ ដើម្បីធានាបាននូវការ

អភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ ដែលកំពុងកើតមានឡើង។

ជាការពិត នៅក្នុងអាណត្តិនៃរាជរដ្ឋាភិបាលនីតិកាលទី៦កន្លងមក រាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់ស៊ីជម្រៅលើវិស័យបរិស្ថាន និងធនធានធម្មជាតិ ដោយបានកែសម្រួលរចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រងរបស់ក្រសួងបរិស្ថាន បង្កើតឱ្យមានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ព្រមទាំងរៀបចំលិខិតបទដ្ឋាន-គតិយុត្តសំខាន់ៗជាច្រើន ជាពិសេសក្រមបរិស្ថាន និងធនធានធម្មជាតិ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងសម្រាប់អព្យាក្រឹតកាបូន សំដៅធានាឱ្យបាននូវគុណភាពបរិស្ថាន តុល្យភាពនៃប្រព័ន្ធអេកូឡូស៊ី ការគ្រប់គ្រងធនធានធម្មជាតិ សុខុមាលភាពសង្គម និងការរស់នៅប្រកបដោយចីរភាព សម្រាប់ជាឧត្តមប្រយោជន៍របស់ប្រជាជនកម្ពុជាគ្រប់ជំនាន់។

ក្នុងគោលបំណងសម្រេចបាននូវបេសកកម្មក្នុងវិស័យបរិស្ថាន និងការអភិវឌ្ឍដោយចីរភាពប្រកបដោយជោគជ័យ **យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន (២០២៣-២០២៨)** បានរៀបចំឡើងដើម្បីតម្រង់ទិស និងចង្អុលបង្ហាញអាទិភាពការងារក្នុងការលើកកម្ពស់កិច្ចគាំពារបរិស្ថាន ការការពារធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយចីរភាព ក្នុងមុំចំនួនបី គឺ «ភាពស្អាត» «ភាពបៃតង» និង «ចីរភាព» សំដៅឆ្ពោះទៅសម្រេចការអភិវឌ្ឍប្រកបដោយអព្យាក្រឹតកាបូននៅឆ្នាំ ២០៥០។ យុទ្ធសាស្ត្រនេះនឹងប្រើប្រាស់ ជាផែនទីបង្ហាញផ្លូវក្នុងការអនុវត្តឱ្យចំគោលដៅអាទិភាព ផ្តល់សេវាសាធារណៈឱ្យចំតម្រូវការរបស់សាធារណជន និងប្រែក្លាយសក្តានុពលវិស័យបរិស្ថាន ឱ្យក្លាយទៅជាឧត្តមប្រយោជន៍បម្រើដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់ជំនាន់ និងចូលរួមចំណែកឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុសកល។

## ២. ចក្ខុវិស័យ

ធានាឱ្យបាននូវចីរភាពបរិស្ថាន និងសុក្រឹតកម្មបរិស្ថានកិច្ច ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងលើកកម្ពស់ការអភិវឌ្ឍបៃតង។

## ៣. បេសកកម្ម

- លើកកម្ពស់ការវិនិយោគបៃតង តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធថាមពលស្អាត ផលិតកម្មវៃឆ្លាត ការដឹកជញ្ជូនបៃតង ការគ្រប់គ្រងសំរាមសំណល់រឹង រាវ ប្លាស្ទិក និងសំណល់គ្រោះថ្នាក់ ការគ្រប់គ្រងគុណភាពខ្យល់ ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ការពង្រីកលំហបៃតង និងការគាំទ្រសេដ្ឋកិច្ចសហគមន៍មូលដ្ឋាន
- ពង្រឹងក្របខណ្ឌគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធនឹងបរិស្ថាន ទឹក ដី ខ្យល់ ជីវៈចម្រុះ ការប្រែប្រួលអាកាសធាតុ និងការទូតបៃតង
- បន្តអភិវឌ្ឍស្ថាប័ន បង្កើនសមត្ថភាពមន្ត្រីជំនាញ និងចំណេះដឹងបច្ចេកទេស ទាំងការសិក្សាស្រាវជ្រាវ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍លើផ្នែកបរិស្ថាន ការអភិវឌ្ឍបៃតង សន្តិសុខទឹក ជីវៈចម្រុះ និងការប្រែប្រួលអាកាសធាតុ។

## ៤. គោលដៅជាយុទ្ធសាស្ត្រ

សម្រេចឱ្យបាននូវ «ភាពស្អាត» «ភាពបៃតង» និង «ចីរភាព» ក្នុងគោលដៅប្រែក្លាយសក្តានុពលវិស័យបរិស្ថាន ឱ្យទៅជាឧត្តមប្រយោជន៍បម្រើជូនប្រជាជាតិកម្ពុជាគ្រប់ជំនាន់ និងលើកតម្កើងកិត្យានុភាពប្រទេសកម្ពុជាលើឆាកអន្តរជាតិ។

យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន (២០២៣-២០២៨) ត្រូវបានរចនាឡើងជារូបរង្វង់ (កងចក្រ) ដោយមាន **យុទ្ធសាស្ត្រស្នូល** ផ្តោតសំខាន់លើមុំបី គឺ ការពង្រឹងគោលនយោបាយ ការកសាងរដ្ឋបាលឌីជីថល និងការពង្រីកការផ្សព្វផ្សាយ ដែលមុំទាំងបីនេះ ជាកម្លាំងចលករជំរុញបង្វិលយុទ្ធសាស្ត្រចំនួនបីផ្សេងទៀត ឱ្យមានដំណើរការដោយភាពរលូននិងប្រសិទ្ធភាព។ យុទ្ធសាស្ត្រទាំងបីនោះ រួមមាន **យុទ្ធសាស្ត្រទី១ ភាពស្អាត** មានមុំបី គឺ ការត្រួតពិនិត្យការបំពុល ការធ្វើទំនើបកម្មប្រព័ន្ធវិនិច្ឆ័យការបំពុល និងការលើកកម្ពស់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន **យុទ្ធសាស្ត្រទី២ ភាពបៃតង** មានមុំបី គឺ ការពង្រីកចលនាដាំដើមឈើ ការជំរុញការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងការលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន និង **យុទ្ធសាស្ត្រទី៣ ចីរភាព** មានមុំបី គឺ ការធ្វើអនុលោមភាព ការពង្រីកកិច្ចសហប្រតិបត្តិការ និងការពង្រឹងការសម្របសម្រួល។

## ៤.១. យុទ្ធសាស្ត្រស្នូល

### មុំទី១ ការពង្រឹងគោលនយោបាយ

**អាទិភាពទី១ ៖ ការលើកកម្ពស់ការរៀបចំ ការអនុវត្ត និងការវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព**

- រៀបចំ **យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន(២០២៣-២០២៨)** ក្នុងរយៈពេល១០០ថ្ងៃដំបូងនៃរាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា
- ពង្រឹងសមត្ថភាពយន្តការនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ ក្រុមការងារបច្ចេកទេសជីវៈចម្រុះ ក្រុមការងាររេដបូកជាតិ (REDD+) និងក្រុមការងារផ្សេងទៀតស្របតាមអាទិភាពនៃយុទ្ធសាស្ត្របញ្ចកោណ

–រៀបចំ និងពង្រឹងសមត្ថភាពក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពឱ្យក្លាយជាស្ថាប័នមានសិទ្ធិទទួលបានមូលនិធិ ដោយផ្ទាល់ពីមូលនិធិអាកាសធាតុបៃតង មូលនិធិបន្សាំនិងមូលនិធិក្នុងវិស័យបរិស្ថានផ្សេងទៀត

–រៀបចំយុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទានបៃតង ដើម្បីគាំទ្រការរៀបចំកម្មវិធី និងគម្រោងពាក់ព័ន្ធវិស័យបរិស្ថាន ការប្រែប្រួលអាកាសធាតុ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍប្រកបដោយចីរភាព

–សិក្សាស្វែងយល់អំពីគំរូនៃឧត្តមានុវត្តពីបណ្តាប្រទេសនានា សម្រាប់ប្រើប្រាស់ជាធាតុចូលក្នុងការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព គោលការណ៍ណែនាំ និងវិញ្ញាបនបត្រនានាពាក់ព័ន្ធវិស័យបរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព

–សិក្សាស្រាវជ្រាវអំពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ពាក់ព័ន្ធវិស័យបរិស្ថាន និងការអភិវឌ្ឍដោយចីរភាព សម្រាប់ជាជម្រើសគោលនយោបាយ វិស័យបរិស្ថាន

–រៀបចំយុទ្ធសាស្ត្រសម្រាប់យុទ្ធនាការសម្អាតប្លាស្ទិក ដែលជាយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិកជំហានទី២ និងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងវិស័យបរិស្ថានផ្សេងទៀត

–រៀបចំ និងសម្របសម្រួលការអនុវត្ត គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពដូចជា (១) យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន (២) យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន (៣) យុទ្ធសាស្ត្រការទូតបៃតង (៤) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព (៥) គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង (៦) ផែនការកំណត់របស់ជាតិក្នុងការរួមចំណែក ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

- រៀបចំ និងសម្របសម្រួលការអនុវត្ត គោលការណ៍ណែនាំ វិញ្ញាបនបត្រ និងរបាយការណ៍បច្ចេកទេសពាក់ព័ន្ធនឹងវិស័យបរិស្ថាន ដោយសហការជាមួយនឹងក្រសួង-ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធនានា
- តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ព្រមទាំងគោលការណ៍ណែនាំ វិញ្ញាបនបត្រ និងរបាយការណ៍បច្ចេកទេសពាក់ព័ន្ធ
- ផ្សព្វផ្សាយ និងចែកចាយ គោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព គោលការណ៍ណែនាំ វិញ្ញាបនបត្រ និងរបាយការណ៍បច្ចេកទេសនានាពាក់ព័ន្ធនឹងវិស័យបរិស្ថាន
- ពង្រឹងសមត្ថភាពមន្ត្រីក្រសួងបរិស្ថាន ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី តាមរយៈកម្មវិធីសិក្សា វេទិកា សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងព្រឹត្តិការណ៍ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ជីវៈចម្រុះ សេដ្ឋកិច្ចបៃតង និងបច្ចេកវិទ្យាបៃតង ក្នុងនិងក្រៅប្រទេស។

### អាទិភាពទី២ ៖ ការចូលរួមក្នុងការរៀបចំ ការអនុវត្ត និងការវាយតម្លៃការអនុវត្តបទប្បញ្ញត្តិនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

- ធ្វើបច្ចុប្បន្នភាព និងដាក់ឱ្យប្រើប្រាស់ ព្រះរាជក្រឹត្យស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងបទប្បញ្ញត្តិពាក់ព័ន្ធទៅនឹងការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- ធ្វើបច្ចុប្បន្នភាព រៀបចំ និងដាក់ឱ្យដំណើរការ ក្រុមការងារអន្តរក្រសួង ក្រុមការងារក្រសួង និងក្រុមការងារផ្សេងទៀត ស្របតាមអាទិភាពជាតិ

-រៀបចំគណៈកម្មាធិការអភិវឌ្ឍន៍ដោយចីរភាពរាជធានី-ខេត្ត ដើម្បីសម្របសម្រួលការងាររបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព នៅក្នុងរាជធានី-ខេត្តសាមី
-សិក្សា និងស្វែងយល់អំពីកាតព្វកិច្ចអន្តរជាតិ និងគោលដៅអភិវឌ្ឍន៍ជាតិដោយចីរភាព គោលការណ៍ណែនាំ និងលិខិតបទដ្ឋានអន្តរជាតិពាក់ព័ន្ធ ដើម្បីពង្រីកលទ្ធភាពនៃការកៀរគរធនធានបច្ចេកទេស និងធនធានថវិកាមកបម្រើឱ្យផលប្រយោជន៍ជាតិ
-រៀបចំវេទិកា កិច្ចប្រជុំ ការពិគ្រោះយោបល់ និងព្រឹត្តិការណ៍ពាក់ព័ន្ធជាមួយក្រុមអ្នកច្បាប់ ដើម្បីតាក់តែងបទប្បញ្ញត្តិនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យបរិស្ថាន
-សម្របសម្រួលកិច្ចការងារ របស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រុមការងារផ្សេងទៀតក្នុងក្របខណ្ឌនៃការរៀបចំអនុវត្ត និងវាយតម្លៃការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តនិងបទប្បញ្ញត្តិពាក់ព័ន្ធ។

### អាទិភាពទី៣ ៖ ការពង្រឹងយន្តការសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន

-រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដើម្បីពិនិត្យអំពីវឌ្ឍនភាពនៃការអនុវត្តការងារ និងតម្រង់ទិសការអនុវត្តការងារពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព
-រៀបចំកិច្ចប្រជុំ ការពិគ្រោះយោបល់ និងព្រឹត្តិការណ៍ពាក់ព័ន្ធនឹង ក្រុមការងារបច្ចេកទេសស្តីពីការប្រែប្រួលអាកាសធាតុ ក្រុមការងារបច្ចេកទេសស្តីពីជីវៈចម្រុះ ក្រុមការងារបច្ចេកទេសរេដបូកជាតិ (REDD+) ក្រុមការងារបច្ចេកទេសថាមពលនិរន្តរភាព ទីក្រុងនិរន្តរភាព អគារបៃតង ការប្រើប្រាស់និងផលិតកម្មនិរន្តរភាព និងក្រុមការងារពាក់ព័ន្ធ

- រៀបចំវេទិកា សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងព្រឹត្តិការណ៍នានា ដើម្បីពង្រីកសមត្ថភាពមន្ត្រី កសាងទំនាក់ទំនង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយនឹងក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន
- សម្របសម្រួល តាមដានការអនុវត្តការងារ និងផ្តល់អនុសាសន៍ជូន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងគណៈកម្មាធិការអភិវឌ្ឍន៍ដោយចីរភាពរាជធានី-ខេត្ត។

## មុំទី២ ការកសាងរដ្ឋបាលឌីជីថល

### អាទិភាពទី១ ៖ ការកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងបំពាក់មធ្យោបាយ ឧបករណ៍ និងសម្ភារទំនើបសម្រាប់ការងាររដ្ឋបាល

- បំពាក់ប្រព័ន្ធព័ត៌មានវិទ្យាទំនើប ដើម្បីគ្រប់គ្រង និងចរាចរឯកសារផ្លូវការក្នុងក្រសួងបរិស្ថានឱ្យមានប្រសិទ្ធភាព
- បង្កើត និងគ្រប់គ្រងមូលដ្ឋានទិន្នន័យ សម្រាប់រក្សាទុក និងគ្រប់គ្រងឯកសារឱ្យបានល្អប្រសើរនិងសម្រាប់ប្រសិទ្ធភាពការងារ
- បំពាក់ឧបករណ៍សម្ភារដូចជា កុំព្យូទ័រ តុការិយាល័យ កៅអី ទូឯកសារ សម្រាប់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងឧទ្យានុរក្ស ដើម្បីឆ្លើយតបទៅនឹងតម្រូវការបច្ចេកទេស កំណើនវិសាលភាពនៃការងារ និងការគ្រប់គ្រងរដ្ឋបាលតាមបែបឌីជីថល
- បំពាក់មធ្យោបាយធ្វើដំណើរដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងឧទ្យានុរក្ស ដើម្បីឆ្លើយតបទៅនឹងតម្រូវការការងារឱ្យកាន់តែមានប្រសិទ្ធភាព
- គ្រប់គ្រងនិងថែទាំ ប្រព័ន្ធព័ត៌មានវិទ្យា ឧបករណ៍សម្ភារការិយាល័យ មធ្យោបាយធ្វើដំណើរ និងអគារបំពេញការងាររបស់ក្រសួង។

## អាទិភាពទី២ ៖ ការកសាងសមត្ថភាពមន្ត្រីរាជការទាំងក្នុងក្របខណ្ឌថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- សិក្សា វាយតម្លៃអំពីតម្រូវការជាក់ស្តែង និងអាទិភាពនៃការកសាងសមត្ថភាពទាំងក្នុងទីស្តីការក្រសួង និងតាមមន្ទីរបរិស្ថានរាជធានី-ខេត្ត
- រៀបចំ វេទិកា សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងព្រឹត្តិការណ៍ពាក់ព័ន្ធ ដើម្បីពង្រឹងសមត្ថភាពមន្ត្រីបម្រើការក្នុងក្រសួង មន្ត្រីនៃមន្ទីរបរិស្ថានរាជធានី-ខេត្ត និងមន្ត្រីឧទ្យានុរក្ស លើការងារគ្រប់គ្រងរដ្ឋបាលការគ្រប់គ្រងធនធានធម្មជាតិ និងកិច្ចគាំពារបរិស្ថាន
- ចាត់បញ្ជូនមន្ត្រីរាជការឱ្យទៅចូលរួមកម្មសិក្សា វេទិកា សិក្ខាសាលា កិច្ចប្រជុំ វគ្គបណ្តុះបណ្តាល និងព្រឹត្តិការណ៍នានា ទាំងក្នុងនិងក្រៅប្រទេស
- លើកទឹកចិត្តដល់មន្ត្រីរាជការ និងអង្គភាពចំណុះដែលបំពេញការងារបានល្អ តាមរយៈ ការផ្តល់គ្រឿងឥស្សរិយយស ការដំឡើងកាំប្រាក់ ការដំឡើងតួនាទី និងការផ្តល់រង្វាន់។

## អាទិភាពទី៣ ៖ ការសាងសង់អគារការិយាល័យបន្ថែម សម្រាប់មន្ត្រីរាជការបំពេញការងារប្រចាំថ្ងៃ និងដាក់ឱ្យដំណើរការ អគារឯកភាពជាតិតេជោ

- បន្តការសាងសង់ អគារឯកភាពជាតិតេជោ ឱ្យបានចប់សព្វគ្រប់តាមផែនការកំណត់ ដើម្បីពង្រីកទំហំនៃទីកន្លែងធ្វើការរបស់មន្ត្រីរាជការ
- សាងសង់ អគារការិយាល័យថ្មី នៅក្នុងបរិវេណទីស្តីការក្រសួង ដើម្បីពង្រីកទំហំកន្លែងធ្វើការ សម្រាប់មន្ត្រីរាជការនិងអ្នកពាក់ព័ន្ធ
- គ្រប់គ្រង និងថែទាំ ឧបករណ៍សម្ភារការិយាល័យ និងអគារបំពេញការងាររបស់ក្រសួង។

## មុំទី៣ ការពង្រីកការផ្សព្វផ្សាយ

### អាទិភាពទី១ ៖ ការបង្កើនចំណេះដឹង និងផ្សព្វផ្សាយព័ត៌មានបរិស្ថាន តាមរយៈប្រព័ន្ធផ្សព្វផ្សាយគ្រប់មធ្យោបាយ

–រៀបចំយុទ្ធនាការនៃការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក នៅក្រោមប្រធានបទ **«ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ»** នៅតាមសាលារៀន រោងចក្រសហគ្រាស និងវិស័យឯកជន

–កៀរគរអង្គការមហាជន និងសប្បុរសជនឱ្យចូលរួមក្នុងយុទ្ធនាការ និងចលនាផ្សេងៗពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងការអភិវឌ្ឍដោយចីរភាព

–ផលិតសម្ភារផ្សព្វផ្សាយរួមមានសារព័ត៌មាន ទស្សនាវដ្តី ផ្ទាំងរូបភាព សម្ភារតាំងពិព័រណ៍ និងសម្ភារផ្សព្វផ្សាយផ្សេងទៀត

–ផ្សព្វផ្សាយសកម្មភាព វឌ្ឍនភាព និងសមិទ្ធផលទាំងឡាយ តាមរយៈបណ្ដាញព័ត៌មានសង្គមនានា រួមមាន កាសែត ទស្សនាវដ្តី គេហទំព័រ Facebook, TikTok, YouTube, Telegram និងតាមរយៈរលកធាតុអាកាស វិទ្យុ ទូរទស្សន៍ ព្រមទាំងតាមរយៈសន្និសីទសារព័ត៌មាន

–ផ្សព្វផ្សាយដល់សាធារណជន អំពីការចូលរួមក្នុងសន្និសីទអន្តរជាតិ វេទិកាសកល និងព្រឹត្តិការណ៍នានានៅបរទេស ដើម្បីទទួលនូវបទពិសោធន៍ល្អៗ និងចំណេះដឹងថ្មីៗពីសកលលោក

–សហការជាមួយប្រព័ន្ធផ្សព្វផ្សាយដូចជា កាសែត ទស្សនាវដ្តី ទូរទស្សន៍ និងវេទិកាព័ត៌មាន Online ដើម្បីពង្រីកវិសាលភាពនៃការផ្សព្វផ្សាយព័ត៌មានបរិស្ថានឱ្យដល់សាធារណជន

- កៀរគរ ទាក់ទាញ អ្នកជំនាញចូលរួមចំណែកបង្កើតអត្ថបទ បំណែកមតិ និងការសម្ភាសន៍ ដើម្បីអប់រំសាធារណជនអំពីបញ្ហាបរិស្ថាន និងវិធានការកែលម្អ
- ពង្រឹងសមត្ថភាពមន្ត្រីរាជការទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការឆ្លើយតបឱ្យទាន់ពេលវេលា ចំពោះបញ្ហាព័ត៌មានមិនពិត
- រៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹង និងការចូលរួមកិច្ចការពារបរិស្ថានតាមរយៈយុទ្ធនាការបរិស្ថាន មានជាអាទិ៍ ការរៀបចំទិវាបរិស្ថាន ការរៀបចំទស្សនកិច្ចសិក្សា ការបោះជំរំ និងវេទិកាបរិស្ថាន
- បញ្ជ្រាបព័ត៌មាន និងចំណេះដឹងដល់សាធារណជន អំពីបច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍ និងចំណេះដឹងប្រពៃណីដូនតាដែលទ្រទ្រង់និរន្តរភាពបរិស្ថាន បន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ បង្កើនសុខមាលភាព និងជីវភាពសហគមន៍មូលដ្ឋាន
- បណ្តុះបណ្តាលមន្ត្រីជំនាញបន្ថែម ក្នុងការផលិតឯកសារផ្សព្វផ្សាយ និងឯកសារវីដេអូផ្សេងៗអំពីប្រធានបទបរិស្ថាន ប្រកបដោយគុណភាព និងភាពទាក់ទាញ។

## អាទិភាពទី២ ៖ ការពង្រីកមជ្ឈមណ្ឌលគ្រប់គ្រងប្រព័ន្ធទិន្នន័យបរិស្ថាន

- សិក្សា និងស្រាវជ្រាវប្រមូលទិន្នន័យនិងព័ត៌មានអំពី គម្របដីព្រៃឈើ ស្តុកកាបូន ជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី ព្យាករណ៍ទឹកជំនន់ គ្រោះរាំងស្ងួត ភ្លើងឆេះព្រៃ ក្នុងតំបន់ការពារធម្មជាតិ
- រៀបចំ និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធវាស់វែង តាមដាន រាយការណ៍ និងការផ្ទៀងផ្ទាត់ជាប្រចាំអំពីគម្របព្រៃឈើ ការប្រើប្រាស់ដីព្រៃឈើ ស្តុកកាបូន

តាមលក្ខខណ្ឌបច្ចេកទេសសមស្រប (Monitoring Reporting and Verification)

- រៀបចំលិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំបច្ចេកទេស ស្តង់ដាគុណភាពទិន្នន័យសម្រាប់ ការគ្រប់គ្រងប្រព័ន្ធព័ត៌មានភូមិសាស្ត្រនៃវិស័យបរិស្ថាន
- បំពាក់ហេដ្ឋារចនាសម្ព័ន្ធចាំបាច់ សម្រាប់មជ្ឈមណ្ឌលគ្រប់គ្រងព័ត៌មានភូមិសាស្ត្រ (GIS) មានទាំងផ្នែករឹងដូចជា Server, Workstations, Storage Devices, Networks និងផ្នែកទន់ដូចជា Web Platform, GIS and Remote Sensing Applications and Tools
- រៀបចំការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍលើបច្ចេកវិទ្យាប្រព័ន្ធព័ត៌មានវិទ្យាថ្មីៗ ដោយសហការជាមួយដៃគូអភិវឌ្ឍន៍ គ្រឹះស្ថានសិក្សាជាតិ និងអន្តរជាតិ ដើម្បីបង្កើនដល់សមត្ថភាពប្រើប្រាស់ឧបករណ៍និងបច្ចេកវិទ្យាពាក់ព័ន្ធនឹងជំនាញថ្មីៗ
- រៀបចំវគ្គបណ្តុះបណ្តាលលើមុខវិជ្ជាជំនាញពាក់ព័ន្ធ សម្រាប់មន្ត្រីក្នុងអង្គភាពទទួលបន្ទុក មន្ត្រីអង្គភាពពាក់ព័ន្ធ និងមន្ត្រីថ្នាក់ក្រោមជាតិ
- រៀបចំបោះពុម្ព និងចែកចាយ របាយការណ៍ស្តីពីស្ថានភាពបរិស្ថាន (Report on the State of Environment) ឱ្យបានទៀងទាត់។

**អាទិភាពទី៣ ៖ ការលើកទឹកចិត្តសាលាមេត្រីបរិស្ថាន អារាមមេត្រីបរិស្ថាន នីតិបុគ្គល និងរូបវន្តបុគ្គលដែលបានចូលរួមក្នុងសកម្មភាពមេត្រីបរិស្ថាន**

- រៀបចំយុទ្ធនាការមេត្រីបរិស្ថានដូចជា យុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ការផ្តល់ជូនឧបករណ៍ប្រព័ន្ធទឹកបរិភោគ ការផ្តល់ជូនធុងទុកដាក់សំរាម ជាដើម

- ធ្វើបច្ចុប្បន្នភាពអំពីនីតិវិធី គោលការណ៍ណែនាំ លក្ខណៈវិនិច្ឆ័យ និងសូចនាករសម្រាប់វាយតម្លៃគុណវុឌ្ឍិប្រតិបត្តិមេត្រីបរិស្ថាន តាមវិស័យនិងសកម្មភាពជាក់លាក់នីមួយៗ
- បោះពុម្ព និងផ្សព្វផ្សាយគោលការណ៍ណែនាំសម្រាប់សាលាមេត្រីបរិស្ថាន និងអារាមមេត្រីបរិស្ថាន
- រៀបចំនីតិវិធី គោលការណ៍ណែនាំ លក្ខណៈវិនិច្ឆ័យ និងសូចនាករសម្រាប់វាយតម្លៃគុណវុឌ្ឍិប្រតិបត្តិមេត្រីបរិស្ថានទៅតាមវិស័យ នៅតាមមូលដ្ឋាន និងសកម្មភាពជាក់លាក់នីមួយៗ
- ផ្សព្វផ្សាយចលនាប្រឡងប្រណាំង «ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព» លើលក្ខណវិនិច្ឆ័យទី៦ តាមគ្រប់រូបភាព
- ផ្តល់ការលើកទឹកចិត្ត និងរង្វាន់ដល់សាលារៀន អារាម ភូមិ ឃុំ-សង្កាត់ នីតិបុគ្គល និងរូបវន្តបុគ្គល ដែលទទួលបានជ័យលាភីមេត្រីបរិស្ថាន
- រៀបចំកម្មវិធីប្រឡងប្រណាំងសាលានិងអារាមមេត្រីបរិស្ថាន នីតិបុគ្គល និងរូបវន្តបុគ្គល ដែលចូលរួមក្នុងសកម្មភាពមេត្រីបរិស្ថាន
- រៀបចំចលនាប្រឡងប្រណាំង «ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព» ជាពិសេស ក្នុងក្របខណ្ឌលក្ខណសម្បត្តិទី៦
- រៀបចំកម្មវិធីប្រកួតប្រជែងដើម្បីស្វែងរកស្នាដៃ និងគំនិតច្នៃប្រឌិតរបស់យុទ្ធនាការទំនាក់ទំនងផ្លាស់ប្តូរឥរិយាបថសង្គម
- ពង្រឹងសមត្ថភាពមន្ត្រីនៃមន្ទីរបរិស្ថានរាជធានី-ខេត្ត ក្នុងការងារអប់រំផ្សព្វផ្សាយ និងវាយតម្លៃ អំពីការប្រតិបត្តិមេត្រីបរិស្ថាន
- ពិនិត្យ សិក្សា និងពិគ្រោះយោបល់ក្នុងការរៀបចំ និងបង្កើតមូលនិធិគាំទ្រដល់ការប្រតិបត្តិមេត្រីបរិស្ថាន និងគំនិតផ្តួចផ្តើមនានា ដែលផ្តោតលើការ

ស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាបៃតង កិច្ចខិតខំប្រឹងប្រែងក្នុងការងារអភិរក្ស ព្រមទាំងកែលម្អលក្ខខណ្ឌបរិស្ថាន។

## ៤.២. យុទ្ធសាស្ត្រទី១ ភាពស្អាត

### មុំទី១ ការត្រួតពិនិត្យការបំពុល

#### អាទិភាពទី១ ៖ ការលើកកម្ពស់ការរៀបចំ អនុវត្ត និងតាមដានប្រព័ន្ធគ្រប់គ្រងសំរាមសំណល់រឹង រាវ ប្លាស្ទិក និងសំណល់គ្រោះថ្នាក់

- រៀបចំអនុក្រឹត្យស្តីពីការគ្រប់គ្រងផលិតផលប្លាស្ទិកប្រើបានតែម្តង និងសំណល់ប្លាស្ទិក អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ប្រកាសស្តីពីសំណក្នុងថ្នាំពណ៌ ប្រកាសស្តីពីប្រភេទបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ប្រកាសស្តីពីការរាយការណ៍អំពីការសាយភាយ និងបម្លាស់ទីសារធាតុបំពុលចូលក្នុងបរិស្ថាន និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត
- ធ្វើបច្ចុប្បន្នភាព និងរៀបចំគោលការណ៍ណែនាំពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំរាមសំណល់រឹង រាវ ដូចជា ការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ការគ្រប់គ្រងសំណល់ពីឱសថ ការគ្រប់គ្រងសំណល់អាគុយ ការគ្រប់គ្រងសំណល់គ្រោះថ្នាក់ចេញពីលំនៅឋាន
- រៀបចំ និងអនុវត្តយុទ្ធនាការសម្អាតប្លាស្ទិក បន្ទាប់ពីយុទ្ធនាការផ្សព្វផ្សាយការកាត់បន្ថយការប្រើប្រាស់ ប្លាស្ទិកជំហានទី១
- ជំរុញការអនុវត្តគោលការណ៍ ៤ក «ការបដិសេធ ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ» នៃសំណល់រឹង ជាពិសេស សំណល់ប្លាស្ទិក
- ជំរុញការញែកសំរាមសំណល់រឹង និងការទុកដាក់ចុងក្រោយ តាមរយៈការរៀបចំទីលានទុកដាក់សំរាមសំណល់រឹងប្រកបដោយសុវត្ថិភាព

- ជំរុញការធ្វើប្រព្រឹត្តិកម្មសម្អាតសំណល់រាវ តាមរយៈការកសាងអាងប្រព្រឹត្តិកម្ម និងបំពាក់បរិក្ខារនៃប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ និងទឹកកខ្វក់
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំណល់រឹង រាវ ប្លាស្ទិក និងសំណល់គ្រោះថ្នាក់ដល់សាធារណជន ជាពិសេស ដល់ម្ចាស់ប្រភពបំពុល
- ពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំណល់រឹង រាវ ប្លាស្ទិក និងសំណល់គ្រោះថ្នាក់
- លើកទឹកចិត្តដល់ការកែច្នៃផលិតផលកសិកម្មនិងរុក្ខជាតិ ឱ្យទៅជាសម្ភារវេចខ្ចប់ ជំនួសឱ្យការប្រើប្រាស់ប្លាស្ទិក
- ពង្រឹងសមត្ថភាពមន្ត្រីក្រសួង និងមន្ទីរបរិស្ថានរាជធានី-ខេត្ត លើការងារគ្រប់គ្រងសំណល់រឹង រាវ ប្លាស្ទិក និងសំណល់គ្រោះថ្នាក់។

**អាទិភាពទី២ ៖ ការធ្វើទំនើបកម្មនៃការគ្រប់គ្រងគុណភាពបរិស្ថាន (ទឹក ដី ខ្យល់ សំឡេង រំញ័រ) ស្របតាមលក្ខខណ្ឌតម្រូវ និងលិខិតបទដ្ឋានគតិយុត្ត**

- សិក្សានិងកំណត់យុទ្ធសាស្ត្រគ្រប់គ្រងគុណភាពបរិស្ថាន (ទឹក ដី ខ្យល់ សំឡេង និងរំញ័រ) ស្របទៅតាមលក្ខខណ្ឌតម្រូវ ដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាពបរិស្ថាន
- រៀបចំអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេងនិងរំញ័រ ប្រកាសស្តីពីការត្រួតពិនិត្យសារធាតុពុលចេញពីយានយន្ត គោលការណ៍ណែនាំបច្ចេកទេសស្តីពីការត្រួតពិនិត្យសារធាតុបំពុលខ្យល់ពីឡចំហាយនិងម៉ាស៊ីនភ្លើង និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត

- ធ្វើបច្ចុប្បន្នភាពក្រុមការងារបច្ចេកទេសអន្តរក្រសួង ដើម្បីពង្រឹងការអនុវត្ត អនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងជាតិ និងអន្តរជាតិពាក់ព័ន្ធ
- បង្កើតស្ថានីយ៍ពិសោធន៍គុណភាពទឹកចល័ត ដើម្បីតាមដានត្រួតពិនិត្យ វិភាគ និងវាយតម្លៃគុណភាពទឹក សម្រាប់ឆ្លើយតបបន្ទាន់ទៅនឹងករណីការបំពុលទឹកនៅតំបន់ទីសាធារណៈ និងបង្កើនទីតាំងត្រួតពិនិត្យតាមដានគុណភាពទឹកសាធារណៈ ពង្រីកស្ថានីយ៍តាមដានគុណភាពទឹកស្វ័យប្រវត្តិ និងបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យឌីជីថល ដើម្បីរាយការណ៍ជាប្រចាំអំពីគុណភាពទឹកសាធារណៈ
- បង្កើតយន្តការតាមដាន និងវាយតម្លៃកម្រិតបំពុលលោហៈធ្ងន់ក្នុងដីដែលស្ថិតនៅក្នុងទីតាំងទីលានចាក់សំណល់រឹង សំណល់ឧស្សាហកម្ម និងទីតាំងប្រកបអាជីវកម្មរ៉ែមាស និងរ៉ែលោហៈនានា ដើម្បីរៀបចំជាផែនទីកំណត់ទីតាំងរងការបំពុល (Hotspot Mapping) និងរៀបចំជាផែនការសម្រាប់ស្តារឡើងវិញ សំដៅលើកកម្ពស់គុណភាពបរិស្ថាន
- រៀបចំគោលការណ៍ណែនាំបច្ចេកទេស និងបំពាក់ឧបករណ៍បច្ចេកទេស ដើម្បីគាំទ្រដល់ការវាយតម្លៃ និងកាត់បន្ថយការរំខានដោយសំឡេងនិងរំញ័រ នៅតំបន់រោងចក្រឧស្សាហកម្ម ការដ្ឋានសំណង់ ការដ្ឋានវាយថ្ម ការដ្ឋានរ៉ែ ជាដើម
- លើកកម្ពស់កិច្ចគាំពារគុណភាពខ្យល់ ការកាត់បន្ថយការរំខានដោយសំឡេងនិងរំញ័រ តាមរយៈការបង្កើតមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យតាមដានគុណភាពខ្យល់ ការបង្កើនស្ថានីយតាមដានគុណភាពខ្យល់តាមគ្រប់ទីប្រជុំជនសំខាន់ៗទូទាំងប្រទេស។

**អាទិភាពទី៣ ៖ ការជំរុញការអនុវត្តគោលនយោបាយគ្រប់គ្រងសំរាម ផ្សារភ្ជាប់ទៅនឹងការអនុវត្តគោលនយោបាយ រិមជ្ឈការ និងវិសហមជ្ឈការ និងគោលនយោបាយភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព**

- ជំរុញការអប់រំផ្សព្វផ្សាយ បណ្តុះបណ្តាលដល់មន្ទីរបរិស្ថាន រដ្ឋបាលថ្នាក់ក្រោមជាតិ ពាក់ព័ន្ធនឹងគោលនយោបាយគ្រប់គ្រងសំណល់រឹង
- សហការចូលរួមត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តគោល-នយោបាយគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន ២០២០-២០៣០
- សិក្សា និងប្រមូលទិន្នន័យអំពីប្រភេទកម្រិតគ្រោះថ្នាក់ និងផលប៉ះពាល់នៃសារធាតុគ្រោះថ្នាក់ សំណល់គ្រោះថ្នាក់ សំណល់វេជ្ជសាស្ត្រ និងសំណល់ដែលមានផ្ទុកសារធាតុវិទ្យុសកម្ម ដែលសាយភាយចូលក្នុង បរិស្ថាន
- ផ្សព្វផ្សាយអំពីកម្រិតគ្រោះថ្នាក់ និងផលប៉ះពាល់នៃសារធាតុគ្រោះថ្នាក់ សំណល់គ្រោះថ្នាក់ សំណល់ វេជ្ជសាស្ត្រ និងសំណល់ដែលមានផ្ទុកសារធាតុវិទ្យុសកម្ម
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងទិន្នន័យសារធាតុបំពុល និងសារធាតុពុលផ្លាស់ទី សម្រាប់ការសិក្សានិងចែករំលែកព័ត៌មាន សំណល់ និងសារធាតុគ្រោះថ្នាក់។

## ទិសទី២ ការធ្វើទំនើបកម្មប្រព័ន្ធវិនិច្ឆ័យការបំពុល

**អាទិភាពទី១ ៖ ការបំពាក់ឧបករណ៍និងបរិក្ខារទំនើប ដើម្បីវិភាគគុណភាពបរិស្ថាន កម្រិតអាស៊ីត សារធាតុវិទ្យុសកម្ម គីមីគ្រោះថ្នាក់ ជីវសាស្ត្រ លោហិតសាស្ត្រ បាក់តេរីសាស្ត្រ និងពន្ធុសាស្ត្រ**

- រៀបចំ និងអនុវត្តនីតិវិធីប្រតិបត្តិប្រកបដោយសុវត្ថិភាពក្នុងមន្ទីរពិសោធន៍ក្នុងការវិភាគនិងវិនិច្ឆ័យការបំពុល

- រៀបចំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធបន្ទប់ពិសោធន៍ តាមស្តង់ដាបច្ចេកទេស និងបំពាក់ឧបករណ៍ បរិក្ខារសម្រាប់ធានាដល់ការធ្វើតេស្តប្រកបដោយគុណភាពនិងសុវត្ថិភាព
- បំពាក់ឧបករណ៍បច្ចេកទេសសម្រាប់ការវិភាគប៉ារ៉ាម៉ែត្រសំខាន់ៗ លើសំណាកបរិស្ថាន តាមវិធីសាស្ត្រវិភាគ រូបសាស្ត្រ គីមីសាស្ត្រ ជីវសាស្ត្រ សេនេទិក និងវិទ្យុសកម្ម
- បង្កើតនិងពង្រឹងការគ្រប់គ្រងសំណល់ចេញពីមន្ទីរពិសោធន៍ ស្របតាមវិធានសុវត្ថិភាព និងសន្តិសុខ
- គ្រប់គ្រងបញ្ជីសារពើភណ្ឌ ថែទាំ ជួសជុល និងធ្វើការផ្ទៀងផ្ទាត់ក្រិតខ្នាតឧបករណ៍ពិសោធន៍ជាប្រចាំ ដើម្បីធានាឱ្យឧបករណ៍ពិសោធន៍ ដំណើរបានត្រឹមត្រូវនិងមានសុក្រឹតភាព
- លើកទឹកចិត្តមន្ត្រីជំនាញក្នុងក្រសួងបរិស្ថាន ឱ្យចូលរួមសហការក្នុងការស្រាវជ្រាវ និងការអនុវត្តគម្រោងនានាជាមួយមន្ទីរពិសោធន៍
- ទទួលនិស្សិតនិងអ្នកស្រាវជ្រាវនានា មកចូលរួមបណ្តុះបណ្តាល និងផ្លាស់ប្តូរបទពិសោធន៍ ក្នុងគោលបំណងចងក្រងទិន្នន័យ និងពង្រឹងសមត្ថភាពលើវិស័យវិទ្យាសាស្ត្របរិស្ថាន។

### អាទិភាពទី២ ៖ ការរៀបចំប្រព័ន្ធគ្រប់គ្រងគុណភាពវិភាគ ដើម្បីធានាលទ្ធផលវិភាគមានគុណភាពនិងសុវត្ថិភាព

- រៀបចំនីតិវិធីសម្រាប់ការគ្រប់គ្រង ការរក្សាទុកសំណាក និងប្រតិករពិសោធន៍ តាមលក្ខណៈបច្ចេកទេស
- រៀបចំ និងដាក់ឱ្យដំណើរការពេញលេញនូវប្រព័ន្ធធានាគុណភាពមន្ទីរពិសោធន៍ និងសៀវភៅណែនាំគុណភាពរបស់មន្ទីរពិសោធន៍

-ពង្រឹងការត្រួតពិនិត្យខាងក្នុងមន្ទីរពិសោធន៍ ទាំងមុនពេលធ្វើតេស្ត ក្នុងពេលធ្វើតេស្ត និងក្រោយពេលធ្វើតេស្ត

-ចូលរួមក្នុងបណ្តាញនៃការវាយតម្លៃគុណភាពមន្ទីរពិសោធន៍ ពីស្ថាប័នខាងក្រៅ ដើម្បីលើកកម្ពស់គុណភាពមន្ទីរពិសោធន៍ក្រសួង

-ចងក្រងនីតិវិធីប្រតិបត្តិវិធីសាស្ត្រវិភាគ និងការត្រួតពិនិត្យគុណភាពសម្រាប់គ្រប់តេស្ត ដើម្បីប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការអនុវត្ត

-សិក្សានិងចងក្រង វិធីសាស្ត្រនិងបច្ចេកវិទ្យាថ្មីៗក្នុងការវិភាគសំណាកបរិស្ថាន ដើម្បីពង្រឹងគុណភាពរបស់មន្ទីរពិសោធន៍

-គ្រប់គ្រងបញ្ជីសារពើភណ្ឌសម្ភារប្រតិករ ធានាដល់ការផ្គត់ផ្គង់បានគ្រប់គ្រាន់ ដើម្បីអនុវត្តបានត្រឹមត្រូវតាមនីតិវិធីប្រតិបត្តិ

-ពង្រឹងសមត្ថភាព និងលើកទឹកចិត្តដល់មន្ត្រីជំនាញជាប្រចាំ ឱ្យស្របនឹងការវិវត្តនៃវិទ្យាសាស្ត្របច្ចេកវិទ្យាក្នុងការធ្វើតេស្តវិភាគ ព្រមទាំងបែងចែកតួនាទីភារកិច្ច និងការទទួលខុសត្រូវមន្ត្រីនៃមន្ទីរពិសោធ៍ឱ្យស្របតាមជំនាញ វិជ្ជាជីវៈ ក្រមសីលធម៌ និងឆន្ទៈក្នុងការបំពេញការងារ។

## អាទិភាពទី៣ ៖ ការពង្រឹងគុណភាពសេវាកម្ម និងសមត្ថភាពមន្ត្រី ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃអតិថិជន

-សិក្សា និងរៀបចំមន្ទីរពិសោធន៍ស្របតាមលក្ខខណ្ឌតម្រូវនៃស្តង់ដាជាតិ និងអន្តរជាតិ ដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងឌីជីថល

-រៀបចំ និងដាក់ឱ្យប្រើប្រព័ន្ធទិន្នន័យមន្ទីរពិសោធន៍ សម្រាប់ការគ្រប់គ្រងការស្នើសុំវិភាគសំណាក ព្រឹត្តិបត្រលទ្ធផលវិភាគ និងសេវាកម្មទូទាត់បានឆាប់រហ័ស ប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព

-សហការជាមួយស្ថាប័នវិភាគការបំពុលអន្តរជាតិ ដើម្បីវាយតម្លៃទទួលស្គាល់គុណភាពនៃការវិភាគជាតិ ជាលក្ខណៈអន្តរជាតិ

-ផ្សព្វផ្សាយរកទីផ្សារដោយបង្ហាញអំពីសមត្ថភាព បច្ចេកទេស សេវាសាធារណៈ ដល់អតិថិជន និងភាគីពាក់ព័ន្ធ

-បង្កើនប្រភេទសេវាកម្មសាធារណៈ (តាមរយៈការពង្រីកប្រភេទតេស្ត និងប៉ារ៉ាម៉ែត្របន្ថែម) ទៅតាមតម្រូវការសាធារណជន

-ធ្វើការស្ទង់មតិអតិថិជនអំពីការផ្តល់សេវារបស់មន្ទីរពិសោធន៍ ដើម្បីរកចំណុចខ្វះខាតសម្រាប់ការកែលម្អជាប្រចាំ។

## មុំទី៣ ការលើកកម្ពស់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

### អាទិភាពទី១ ៖ ការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

-រៀបចំគោលនយោបាយបរិស្ថានជាយុទ្ធសាស្ត្រ ប្រកាសស្តីពីគំរូលក្ខខណ្ឌការងារសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងសម្រាប់គម្រោងស្វែងរុករករ៉ែលោហៈ ប្រកាសអន្តរក្រសួង រវាងក្រសួងបរិស្ថាន ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការដ្ឋានក្រោយអាជីវកម្ម ព្រមទាំងគោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត

-សិក្សានិងដំឡើងកម្រិត នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានឱ្យក្លាយជាអគ្គនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

-រៀបចំ និងគ្រប់គ្រងប្រព័ន្ធសម្រាប់ប្រមូលមូលនិធិទាយជ្ជទានបរិស្ថាន និងមូលនិធិបរិស្ថាននិងសង្គម តាមប្រព័ន្ធធនាគារ និងប្រព័ន្ធឌីជីថល។

**អាទិភាពទី២ ៖ ការសិក្សា និងការវាយតម្លៃគម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគឯកជន ដើម្បីរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងកិច្ចសន្យាការពារបរិស្ថាន**

- ពិនិត្យ សិក្សា វិភាគ និងផ្ដល់យោបល់ លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ព្រមទាំងកិច្ចសន្យាបរិស្ថាន
- ធ្វើចំណាត់ថ្នាក់គម្រោង និងលក្ខខណ្ឌការងារ ដើម្បីកំណត់កម្រិតនៃការវាយតម្លៃ មានដូចជាការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមពេញលេញ ព្រមទាំងកិច្ចសន្យាការពារបរិស្ថាន
- ចុះត្រួតពិនិត្យដល់ទីតាំងជាក់ស្ដែង សម្រាប់គម្រោងដែលត្រូវវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង និងពេញលេញ
- សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ដើម្បីសម្របសម្រួលការអនុវត្តនីតិវិធី នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម
- រៀបចំវគ្គបណ្ដុះបណ្ដាល ការផ្សព្វផ្សាយ បទដ្ឋានគតិយុត្ត នីតិវិធីលើការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម និងបង្កើនប្រសិទ្ធភាពការពិនិត្យ និងវាយតម្លៃគម្រោងអភិវឌ្ឍន៍ពាក់ព័ន្ធ។

**អាទិភាពទី៣ ៖ ការតាមដាន និងការវាយតម្លៃនៃការអនុវត្តគម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគឯកជន ដើម្បីធានាការអនុវត្តតាមគោលការណ៍បរិស្ថាន**

- រៀបចំក្រុមការងារ ដើម្បីចុះតាមដាននិងវាយតម្លៃការអនុវត្តគម្រោងវិនិយោគសាធារណៈ និងគម្រោងវិនិយោគឯកជន

- ចុះអង្កេតតាមដានជាប្រចាំ លើការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ផ្អែកទៅតាមរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងកិច្ចសន្យាការពារបរិស្ថាន
- ជំរុញសកម្មភាព និងការប្រមូលមូលនិធិទាយជ្ជទានបរិស្ថាន និងមូលនិធិបរិស្ថាននិងសង្គម តាមប្រព័ន្ធធនាគារ និងប្រព័ន្ធគ្រប់គ្រងឌីជីថល។

## ៤.៣. យុទ្ធសាស្ត្រទី២ ភាពបៃតង

### មុំទី១ ការពង្រីកចលនាដាំដើមឈើ

**អាទិភាពទី១ ៖ ការផ្តល់កូនឈើដល់សាធារណជន យ៉ាងតិចចំនួន១លានដើមក្នុងមួយឆ្នាំ**

- រៀបចំថ្នាលបណ្តុះកូនឈើនៅគ្រប់មន្ទីរបរិស្ថានរាជធានី-ខេត្ត ដើម្បីចែកចាយដល់សាធារណជនទូទៅដោយឥតគិតថ្លៃ
- រៀបចំគោលការណ៍ណែនាំបច្ចេកទេស សម្រាប់ការបង្កើតថ្នាលបណ្តុះកូនឈើ ការដាំដើមឈើ និងការដាំស្តារព្រៃឈើ
- ចែកចាយកូនឈើជូនដល់សាធារណជន យ៉ាងតិច១លានដើមក្នុងមួយឆ្នាំ ដោយឥតគិតថ្លៃសម្រាប់ការដាំដុះតាមទីសាធារណៈ និងតាមទីតាំងឯកជន
- ចូលរួមអបអរសាទរ «រុក្ខទិវា៩កក្កដា» និងអនុវត្តការដាំដើមឈើ ដោយមានការចូលរួមពីសាធារណជន
- បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យឌីជីថល ដើម្បីកំណត់អត្តសញ្ញាណដើមឈើ និងតាមដានការលូតលាស់នៃដើមឈើ ដែលបានដាំដោយសាធារណជន។

## អាទិភាពទី២ ៖ ការពង្រីកការដាំដើមឈើក្នុងព្រៃរេចរឹលនៃតំបន់ការពារធម្មជាតិ

- រៀបចំផែនការសម្រាប់ការដាំស្តារព្រៃឈើឡើងវិញ ក្នុងតំបន់ព្រៃរេចរឹលនៃតំបន់ការពារធម្មជាតិ ដើម្បីពង្រីកគម្របព្រៃឈើឈានឆ្ពោះទៅគោលដៅគម្របព្រៃឈើ ៦០ភាគរយ នៅឆ្នាំ២០៥០
- ពង្រីកការរៀបចំថ្នាលបណ្តុះកូនឈើ នៅគ្រប់មន្ទីរបរិស្ថានរាជធានី-ខេត្ត ដើម្បីអនុវត្តការដាំស្តារព្រៃឈើ ក្នុងតំបន់ព្រៃរេចរឹលនៃតំបន់ការពារធម្មជាតិ
- រៀបចំសកម្មភាពដាំ និងស្តារព្រៃឈើនៅតំបន់ការពារធម្មជាតិក្នុងឱកាសទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ដែលប្រព្រឹត្តឡើងទៅជារៀងរាល់ឆ្នាំ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ឬព្រះរាជតំណាង និងបញ្ជ្រាបការដាំកូនឈើនៅគ្រប់ទីកន្លែង ឧទាហរណ៍ វត្តអារាម សាលារៀន រោងចក្រ សហគ្រាស ទីប្រជុំជន
- ថែទាំ និងតាមដានការដាំស្តារព្រៃឈើឡើងវិញនៅក្នុងតំបន់ព្រៃរេចរឹលនៃតំបន់ការពារធម្មជាតិ ដើម្បីធានាអត្រាដុះលូតលាស់ឱ្យបានល្អប្រសើរ។

## អាទិភាពទី៣ ៖ ការបង្កើនការដាំដើមឈើក្នុងសហគមន៍តំបន់ការពារធម្មជាតិ

- រៀបចំផែនការដាំឈើក្នុងសហគមន៍តំបន់ការពារធម្មជាតិ ដើម្បីពង្រីកគម្របព្រៃឈើ ឈានឆ្ពោះទៅរកគោលដៅ សហគមន៍អព្យាក្រឹតកាបូន
- ពង្រីកការរៀបចំថ្នាលបណ្តុះកូនឈើក្នុងសហគមន៍តំបន់ការពារធម្មជាតិ សម្រាប់ការដាំដើមឈើក្នុងតំបន់នៃសហគមន៍មូលដ្ឋាន
- រៀបចំសកម្មភាពដាំដើមឈើ នៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ និងដាំដើមឈើហូបផ្លែនៅតាមភូមិឋានរបស់ប្រជាសហគមន៍
- ថែទាំ និងតាមដានការដាំដើមឈើនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ ដើម្បីធានានូវអត្រាដុះលូតលាស់ឱ្យបានល្អប្រសើរ

- ទាក់ទាញការវិនិយោគមកបណ្តាក់ទុន នៅក្នុងការដាំដុះផល-អនុផលព្រៃឈើ សម្រាប់ការកែច្នៃសំដៅបង្កើនគម្របព្រៃតងផង និងបង្កើនប្រាក់ចំណូលបន្ថែមដល់ប្រជាសហគមន៍ផង។

## មុំទី២ ការជំរុញការគ្រប់គ្រងតំបន់ការពារធម្មជាតិ

### អាទិភាពទី១ ៖ ការពង្រឹងការគ្រប់គ្រង ឧទ្យានជាតិ ដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង តំបន់រ៉ាមសារ តំបន់បេតិកភណ្ឌធម្មជាតិ និងឧទ្យានជាតិសមុទ្រ

- រៀបចំ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្ត សម្រាប់គាំទ្រ និងគ្រប់គ្រងតំបន់ការពារធម្មជាតិ ស្របតាមក្រមបរិស្ថាននិងធនធានធម្មជាតិ
- បន្តកំណត់ព្រំប្រទល់ បោះបង្គោលព្រំ និងចុះបញ្ជីដីតំបន់ការពារធម្មជាតិ និងបែងចែកតំបន់គ្រប់គ្រង និងរៀបចំផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិនីមួយៗ
- ធ្វើចំណាត់ថ្នាក់ព្រៃឈើ និងសិក្សាទីជម្រាលក្នុងតំបន់ការពារធម្មជាតិ និងធ្វើបច្ចុប្បន្នភាពគម្របព្រៃឈើ សារពើព័ន្ធតំបន់ដីសើម តំបន់ដីមមោក ព្រៃកោងកាង និងប្រព័ន្ធអេកូឡូស៊ី
- ពង្រឹងការអនុវត្តច្បាប់ក្នុងការអភិរក្សព្រៃឈើ សត្វព្រៃ វារីសត្វក្នុងតំបន់ការពារធម្មជាតិ ដោយគោរពតាមគោលការណ៍៤ចំណុច គឺអនុវត្តច្បាប់ពេញលេញ ពង្រឹងកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន ពង្រីកកិច្ចសហការជិតស្និតជាមួយគណៈកម្មាធិការជាតិ ទប់ស្កាត់បទល្មើសធនធានធម្មជាតិ និងជំរុញការដាំស្តារព្រៃឈើឡើងវិញ

- ពង្រីកការអប់រំផ្សព្វផ្សាយអំពីសក្តានុពលធនធានធម្មជាតិ ជីវៈចម្រុះ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី នៅក្នុងតំបន់ការពារធម្មជាតិដល់សាធារណជន តាមរយៈការរៀបចំវេទិកា ពិព័រណ៍ និងព្រឹត្តការណ៍ផ្សេងៗទៀត
- ធ្វើទំនើបកម្មឌីជីថលូបនីយកម្ម អង្គភាពគ្រប់គ្រងតំបន់ការពារធម្មជាតិ និងកសាងហេដ្ឋារចនាសម្ព័ន្ធល្បាត និងគ្រប់គ្រងតំបន់ការពារធម្មជាតិ។

## អាទិភាពទី២ ៖ ការលើកកម្ពស់ការអភិរក្សជីវៈចម្រុះ

- សិក្សា និងស្រាវជ្រាវអំពីប្រភេទរុក្ខជាតិនិងសត្វព្រៃ ដែលកំពុងមានវត្តមាននៅក្នុងតំបន់ការពារធម្មជាតិ ដើម្បីរៀបចំផែនការនិងសកម្មភាពសម្រាប់ការគ្រប់គ្រងនិងអភិរក្ស
- រៀបចំចំណាត់ថ្នាក់ និងបញ្ជីប្រភេទជីវៈចម្រុះងាយរងគ្រោះ និងជិតផុតពូជ សម្រាប់ជាមូលដ្ឋានក្នុងការអភិរក្សសេនេទិកជីវៈចម្រុះ ការរៀបចំផែនការអភិរក្សជីវៈចម្រុះ និងការចុះបញ្ជីកម្មសិទ្ធិបញ្ញា
- ការពារ និងស្តារទីជម្រកសត្វព្រៃក្នុងតំបន់ការពារធម្មជាតិ ដើម្បីសុខដុមនីយកម្មរវាងសត្វព្រៃនិងមនុស្ស សំដៅពង្រឹងការអភិរក្សជីវៈចម្រុះ និងលើកកម្ពស់វិស័យទេសចរណ៍ធម្មជាតិ
- អភិរក្ស និងស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីដែលសឹករេចរឹល ដើម្បីរក្សាបាននូវសេវាកម្មប្រព័ន្ធអេកូឡូស៊ី លំនឹងខ្សែច្រវាក់ចំណីអាហារ និងសុខុមាលភាពសហគមន៍
- រៀបចំ និងអនុវត្តវិធានការសម្អាតសំណល់រឹង ជាពិសេសប្លាស្ទិកដែលធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ និងគុណភាពបរិស្ថានក្នុងបឹងទន្លេសាបនិងប្រភពទឹកនានា។

### អាទិភាពទី៣ ៖ ការពង្រឹងយន្តការតាមដានការប្រែប្រួលគម្របព្រៃឈើ

- កសាងប្រព័ន្ធទិន្នន័យគោល (Sever Database) តំបន់ការពារធម្មជាតិ និងការអនុវត្តច្បាប់ (Protected Area Sever Database)
- កសាងសមត្ថភាពមន្ត្រីជំនាញក្នុងការចងក្រង វិភាគ និងគ្រប់គ្រងទិន្នន័យឌីជីថល និងការចុះផ្ទៀងផ្ទាត់ទិន្នន័យនៅទីវាល
- ពង្រឹងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រង ការតាមដាន រាយការណ៍ ចំពោះការប្រែប្រួលនៃគម្របព្រៃឈើក្នុងតំបន់ការពារធម្មជាតិ។

## មុំទី៣ ការលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន

### អាទិភាពទី១ ៖ ការលើកកម្ពស់សន្តិសុខស្បៀង អាហារូបត្ថម្ភ និងការរស់នៅស្អាតរបស់ប្រជាសហគមន៍ តាមរយៈ ការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ និងការប្រើប្រាស់ថាមពលស្អាត

- ផ្សព្វផ្សាយអំពីការប្រែប្រួលអាកាសធាតុ និងវិបត្តិអាកាសធាតុនានា ដើម្បីឱ្យប្រជាសហគមន៍ យល់ដឹងនិងមានវិធានការបន្សុាំក្នុងការដាំដុះ និងការចិញ្ចឹមសត្វ
- ផ្សព្វផ្សាយការគ្រប់គ្រង ការកែច្នៃសំណល់ និងការកាត់បន្ថយការប្រើ-ប្រាស់ថង់ប្លាស្ទិក ដើម្បីឱ្យប្រជាសហគមន៍ យល់ដឹងនិងមានវិធានការក្នុងការរស់នៅស្អាត
- ជំរុញការអនុវត្តកសិរុក្ខកម្ម ក្សេត្របរិស្ថាន និងបច្ចេកវិទ្យាកសិកម្មវៃឆ្លាតដែលធន់នឹងការប្រែប្រួលអាកាសធាតុ ដើម្បីបង្កើតការងារបៃតងនិងប្រាក់ចំណូលបន្ថែមដល់ប្រជាសហគមន៍
- ជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញ ប្រកបដោយនិរន្តរភាព ដើម្បីចូលរួមឆ្លើយតបនឹងការ ប្រែប្រួលអាកាសធាតុសកល

- ពង្រីកប្រភពទឹក និងបង្កើនគុណភាពទឹក សម្រាប់ការស្រោចស្រពនិងប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាសហគមន៍
- លើកកម្ពស់អាហារូបត្ថម្ភ និងវិធានការសុខភាព អនាម័យ ដល់ប្រជា-សហគមន៍ ជាពិសេសក្រុមជនងាយរងគ្រោះតាមរយៈការអប់រំផ្សព្វផ្សាយនិងការគាំទ្រការអនុវត្ត។

## អាទិភាពទី២ ៖ ការលើកកម្ពស់ជីវភាពប្រជាសហគមន៍ តាមរយៈ ការបង្កើនប្រាក់ចំណូលពីទេសចរណ៍ធម្មជាតិនិងវប្បធម៌ និងជម្រើសមុខរបរសមស្រប

- ពង្រឹងបរិយាកាសអំណោយផលសម្រាប់វិស័យទេសចរណ៍ធម្មជាតិ តាមរយៈការរៀបចំលិខិតបទដ្ឋានគតិយុត្ត ហេដ្ឋារចនាសម្ព័ន្ធ និងសម្បទានទេសចរណ៍ធម្មជាតិ ព្រមទាំងកិច្ចសហប្រតិបត្តិការជាមួយនឹងស្ថាប័នពាក់ព័ន្ធនិងវិស័យឯកជន
- ពង្រឹងសមត្ថភាពសិក្សាស្រាវជ្រាវ អំពីការអភិវឌ្ឍទេសចរណ៍ធម្មជាតិទៅលើសក្តានុពលនៃតំបន់ទេសចរណ៍ធម្មជាតិ ការបង្កើតជាទស្សនវិស័យ និងផែនការអភិវឌ្ឍទេសចរណ៍
- ពង្រឹង និងពង្រីកការផ្សព្វផ្សាយអំពីការអភិវឌ្ឍទេសចរណ៍ធម្មជាតិ ដោយផ្តោតលើគុណភាពផលិតផល និងសេវាកម្មទេសចរណ៍ធម្មជាតិ រួមទាំងវិធានការអនាម័យ ការគ្រប់គ្រងសំរាមសំណល់រឹង និងការប្រើប្រាស់ថាមពលស្អាតនៅក្នុងតំបន់ទេសចរណ៍ធម្មជាតិ
- បង្កើត និងអភិវឌ្ឍរបៀងសហគមន៍ទេសចរណ៍ធម្មជាតិ និងវប្បធម៌ដែលមានលក្ខណៈបំពេញឱ្យគ្នាទៅវិញទៅមក
- ធ្វើពិពិធកម្មមុខរបរ ដើម្បីលើកកម្ពស់ជីវភាពសហគមន៍តំបន់ការពារធម្មជាតិ ដើម្បីកាត់បន្ថយការពឹងផ្អែកទៅលើធនធានធម្មជាតិ

- បង្កើន និងពង្រឹងយន្តការសម្របសម្រួលការអភិវឌ្ឍទេសចរណ៍ធម្មជាតិ ពីគ្រប់ភាគីពាក់ព័ន្ធ យន្តការហិរញ្ញប្បទានគាំទ្រដល់ការអភិវឌ្ឍសហគមន៍ និងការអភិរក្សជីវៈចម្រុះ យន្តការត្រួតពិនិត្យនិងវាយតម្លៃការអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងយន្តការចាំបាច់ផ្សេងទៀត។

### អាទិភាពទី៣ ៖ ការពង្រឹងការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិនិងវប្បធម៌ តាមរយៈ ការពង្រីកគម្របព្រៃឈើ និងការលើកកម្ពស់តម្លៃនៃបេតិកភណ្ឌធម្មជាតិ វប្បធម៌ និងប្រពៃណីទំនៀមទម្លាប់

- រៀបចំ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្ត ដើម្បីគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ បេតិកភណ្ឌធម្មជាតិ និងវប្បធម៌ក្នុងតំបន់ការពារធម្មជាតិ ស្របទៅតាមក្រមបរិស្ថាននិងធនធានធម្មជាតិ
- ពង្រឹង និងពង្រីកការសិក្សាស្រាវជ្រាវតំបន់បុរាណស្ថាន និងស្ថានីយផូស៊ីល ទាំងនៅក្នុងនិងក្រៅតំបន់ការពារធម្មជាតិ
- ពង្រឹងដំណើរការ និងការគ្រប់គ្រងបណ្តាញសហគមន៍អភិរក្សធនធានធម្មជាតិ និងបណ្តាញស្ត្រីក្នុងតំបន់ការពារធម្មជាតិ
- ពង្រឹងសមត្ថភាពមន្ត្រីថ្នាក់ក្រោមជាតិ និងគណៈកម្មការសហគមន៍ លើជំនាញកសិ-រុក្ខកម្ម ការដកហូត និងកែច្នៃអនុផលព្រៃឈើប្រកបដោយនិរន្តរភាព និងការងារគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ
- ពង្រឹង និងពង្រីកកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងដៃគូអភិវឌ្ឍន៍ លើការផ្សព្វផ្សាយ បង្កើត គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់បេតិកភណ្ឌធម្មជាតិ និងធនធានធម្មជាតិ

–ពង្រីកវិសាលភាពផ្ទៃដីគម្របព្រៃឈើ និងស្ដារគម្របព្រៃឈើឡើងវិញ ដើម្បីជានានិរន្តរភាព និងលើកកម្ពស់ផលប្រយោជន៍សេដ្ឋកិច្ច និងតម្លៃនៃផល-អនុផលព្រៃឈើ

–កាត់បន្ថយភាពងាយរងគ្រោះរបស់ព្រៃឈើ និងបង្កើនភាពធន់នៃព្រៃឈើទៅនឹងការប្រែប្រួលអាកាសធាតុ

–លើកកម្ពស់ការថែរក្សាប្រពៃណី ទំនៀមទម្លាប់របស់សហគមន៍មូលដ្ឋាន ជាពិសេស ជនជាតិដើមភាគតិចក្នុងតំបន់ការពារធម្មជាតិ។

## ៤.៤. យុទ្ធសាស្ត្រទី៣ ចីរភាព

### មុំទី១ ការអនុវត្តអនុលោមភាព

#### អាទិភាពទី១ ៖ ការអនុលោមតាម កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា សម្រាប់ការកសាងនិងការពារមាតុភូមិ ឆ្នាំ២០២៣-២០២៨

–គោលដៅជាយុទ្ធសាស្ត្រទី១ ការពារសន្តិភាព ការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី និងការពាររាល់សមិទ្ធផលនៃសង្គមជាតិឱ្យបានគង់វង្ស ស្ថិតស្ថេរ

–គោលដៅជាយុទ្ធសាស្ត្រទី២ កសាងព្រះរាជាណាចក្រកម្ពុជា ជារដ្ឋប្រជាធិបតេយ្យសេរីពហុបក្សដ៏ជឿនលឿន និងរឹងមាំដែលផ្អែកលើច្បាប់ មានសេដ្ឋកិច្ចរីកចម្រើនប្រកបដោយចីរភាពនិងសមធម៌ ប្រជាជនមានជីវភាពសម្បូរសប្បាយ រស់នៅយ៉ាងសុខដុមរមនាប្រកបដោយកិត្តិយសសេចក្ដីថ្លៃថ្នូរ និងមានការគោរពសិទ្ធិមនុស្ស

- គោលដៅជាយុទ្ធសាស្ត្រទី៣ កសាងប្រព័ន្ធគាំពារសង្គមប្រកបដោយបរិយាបន្ន ប្រសិទ្ធភាព និងចីរភាពហិរញ្ញវត្ថុ ដែលធានាការផ្តល់ការគាំពារដល់ប្រជាជនក្នុងការឆ្លើយតបនឹងហានិភ័យសេដ្ឋកិច្ច ហានិភ័យសុខភាពសាធារណៈ និងភាពងាយរងគ្រោះផ្សេងៗ ដែលកើតឡើងពីការប្រែប្រួលលក្ខខណ្ឌនៃការងារនិងការរស់នៅ
- គោលដៅជាយុទ្ធសាស្ត្រទី៤ ជំរុញការអនុវត្ត «កម្ពុជាគ្មានមីនត្រឹមឆ្នាំ ២០២៥» និងកាត់បន្ថយគ្រាប់មីនមិនទាន់ផ្ទុះឱ្យបានជាអតិបរិមា
- គោលដៅជាយុទ្ធសាស្ត្រទី៥ បន្តអនុវត្តគោលនយោបាយការបរទេសឯករាជ្យដោយផ្អែកលើច្បាប់ កសាងមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អប្រសើរ រវាងព្រះរាជាណាចក្រកម្ពុជាជាមួយប្រទេសទាំងអស់នៅលើសកលលោក និងអង្គការអន្តរជាតិនានា ហើយចូលរួមយ៉ាងសកម្មចំពោះបុព្វហេតុសន្តិភាព ស្ថិរភាព សន្តិសុខ និងវិបុលសុខ ក្នុងតំបន់និងពិភពលោក។

### អាទិភាពទី២ ៖ ការអនុលោមតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១

**- បញ្ចកោណទី២**

- មុំទី១ ការអភិវឌ្ឍវិស័យគន្លឹះ និងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច
- មុំទី២ ការលើកកម្ពស់ការតភ្ជាប់ និងការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូននិងឡូជីស្ទីក វិស័យថាមពល វិស័យទឹកស្អាត និងវិស័យឌីជីថល
- មុំទី៤ ការពង្រឹងប្រសិទ្ធភាព និងភាពទាក់ទាញនៃតំបន់សេដ្ឋកិច្ចពិសេស រួមបញ្ចូលនូវសួនឧស្សាហកម្ម សួនកសិ-ឧស្សាហកម្ម និងតំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក
- មុំទី៥ ការធ្វើនវានុវត្តយន្តការហិរញ្ញប្បទាន និងផលិតផលហិរញ្ញវត្ថុសម្រាប់គាំទ្រដល់ការវិនិយោគ

-បញ្ញកោណទី៤

- មុំទី២ ការគ្រប់គ្រងធនធានធម្មជាតិ បេតិកភណ្ឌវប្បធម៌ និងទេសចរណ៍ប្រកបដោយចីរភាព ដែលគោលដៅជាយុទ្ធសាស្ត្រនេះ គឺការផ្តោតលើការអភិរក្សដើម្បីការអភិវឌ្ឍ សំដៅលើកកម្ពស់ ការអភិវឌ្ឍវិស័យកសិកម្មឧស្សាហកម្ម និងទេសចរណ៍ ការពង្រឹងការគ្រប់គ្រងធនធានរ៉ែ ការធានាចីរភាពធនធានព្រៃឈើ ជលផល និងគុណភាពដី ព្រមទាំងការការពារការអភិវឌ្ឍ និងការទាញយកប្រយោជន៍ឱ្យអស់សក្តានុពលពីបេតិកភណ្ឌវប្បធម៌ និងទេសចរណ៍ប្រកបដោយចីរភាព
- មុំទី៤ ពង្រឹងការគ្រប់គ្រង និងការធ្វើទំនើបកម្មនគរូបនីយកម្ម ដែលគោលដៅជាយុទ្ធសាស្ត្រនេះ គឺការពង្រីកទីក្រុង និងការអភិវឌ្ឍទីក្រុងថ្មីៗបន្ថែម នៅតាមបណ្តារាជធានី-ខេត្ត ការបង្កើតសួន សាធារណៈ និងឧទ្យានបៃតង និងការពង្រឹងការគ្រប់គ្រងនិងការធ្វើទំនើបកម្មនគរូបនីយកម្ម ដើម្បីធានាសុវត្ថិភាព សោភ័ណភាព បរិស្ថានល្អ និងសុខុមាលភាពសម្រាប់ការរស់នៅ និងប្រសិទ្ធភាពក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច
- មុំទី៥ ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំង ការលើកកម្ពស់សេដ្ឋកិច្ចបៃតងគោលដៅជាយុទ្ធសាស្ត្រ គឺការកាត់បន្ថយការបំពុល និងផលប៉ះពាល់បរិស្ថាន ការពង្រឹងការគ្រប់គ្រងទឹក និងការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងការចូលរួមចំណែកក្នុងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុសកល ដើម្បីធានាការអភិវឌ្ឍដោយចីរភាព

-បញ្ញកោណទី៥

- មុំទី១ ការកសាងរដ្ឋាភិបាលឌីជីថល និងពលរដ្ឋឌីជីថល ដោយផ្តោតលើការដឹកនាំការធ្វើបរិវត្តកម្មឌីជីថល ដោយរាជរដ្ឋាភិបាលធ្វើជាគំរូដឹកមុខក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថល តាមរយៈការធ្វើឌីជីថលភាវូបនីយកម្មកិច្ចការសាធារណៈរបស់រដ្ឋ ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈសម្រាប់ប្រជាជន និងវិស័យឯកជន ព្រមទាំងការពង្រឹងអភិបាលកិច្ចផ្អែកលើទិន្នន័យ
- មុំទី៣ ការកសាង និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដោយផ្តោតលើការកសាងនិងការពង្រីកហេដ្ឋារចនាសម្ព័ន្ធឌីជីថល រួមមានការតភ្ជាប់ឌីជីថល និងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ និងឃ្លាំងមជ្ឈមណ្ឌលទិន្នន័យ សំដៅពង្រឹងគុណភាពនិងប្រសិទ្ធភាពចំពោះបណ្តាញតភ្ជាប់ឌីជីថល ការចែករំលែកព័ត៌មាន និងការផ្តល់សេវាទូរគមនាគមន៍
- មុំទី៤ ការកសាងភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល ដោយផ្តោតលើការកសាងភាពជឿទុកចិត្តលើប្រព័ន្ធឌីជីថល តាមរយៈការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងយន្តការស្ថាប័នសន្តិសុខឌីជីថល និងការលើកកម្ពស់នៃការយល់ដឹងអំពីសន្តិសុខឌីជីថល ដើម្បីជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលឱ្យបានទូលំទូលាយ

**អាទិភាពទី៣ ៖ ការអនុលោមតាម គោលនយោបាយ យុទ្ធសាស្ត្រ និង បទដ្ឋានគតិយុត្តជាតិពាក់ព័ន្ធ និង អនុសញ្ញា ពិធីសារ កិច្ចព្រមព្រៀងអន្តរជាតិនានា**

-ដឹកនាំ សម្របសម្រួល និងបន្តអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តជាតិពាក់ព័ន្ធមានដូចជា សៀវភៅ «ស» វិស័យ

បរិស្ថាន ការអភិវឌ្ឍន៍ដោយចីរភាព ព្រមទាំងក្រុមបរិស្ថាននិងធនធានធម្មជាតិ

- ដឹកនាំ សម្របសម្រួល និងចូលរួមអនុវត្តអនុសញ្ញាអន្តរជាតិពាក់ព័ន្ធមានជាអាទិ៍ អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ អនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ កិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ស្តីពីការប្រែប្រួលអាកាសធាតុ អនុសញ្ញាអន្តរជាតិ ពិធីសារ ព្រមទាំងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនានា
- លើកយោបល់ទាក់ទងនឹងគោលជំហរ និងយុទ្ធសាស្ត្រជាតិ សម្រាប់ជាជាតុចូលក្នុងការអនុវត្តអនុសញ្ញាអន្តរជាតិ ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធ សំដៅពង្រឹងភាពជាម្ចាស់ (Ownership) ក្នុងការអនុវត្តយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន
- កសាងសមត្ថភាពស្ថាប័នរដ្ឋ មានជាអាទិ៍ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ជាដើម ឱ្យក្លាយជា «អង្គភាពទទួលស្គាល់ Accredited Entity» ពីមូលនិធិអាកាសធាតុបៃតង មូលនិធិបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងមូលនិធិដទៃទៀត
- សម្របសម្រួល សហការ និងកៀរគរការគាំទ្រ ដើម្បីអនុវត្តការងារស្របតាមគោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តថ្នាក់ជាតិពាក់ព័ន្ធ ព្រមទាំងអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិ។

## មុំទី២ ការពង្រីកកិច្ចសហប្រតិបត្តិការ

### អាទិភាពទី១ ៖ ការលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន

- ដឹកនាំការសម្របសម្រួល ការអនុវត្ត និងការវាយតម្លៃនៃការអនុវត្តគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការ

សកម្មភាព កម្មវិធី និងគម្រោងពាក់ព័ន្ធវិស័យ បរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព

- ដឹកនាំ និងសម្របសម្រួលការងារសេដ្ឋកិច្ចបៃតង ការប្រែប្រួលអាកាសធាតុ ការអភិរក្សជីវៈចម្រុះ និងជីវសុវត្ថិភាព
- លើកយោបល់បញ្ជាក់ពីជំហរ និងយុទ្ធសាស្ត្រជាតិ សម្រាប់ចូលរួមក្នុងកិច្ចព្រមព្រៀង កិច្ចប្រជុំ និងការចរចាអន្តរជាតិនានា ដែលពាក់ព័ន្ធទៅនឹងវិស័យបរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព
- ផ្សព្វផ្សាយ និងចែករំលែកនូវបទពិសោធន៍ល្អៗ ព្រមទាំងភាពជោគជ័យសំខាន់ៗ ដែលក្រសួងសម្រេចបានជូនដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានឱ្យបានយល់ដឹងនិងប្រតិបត្តិតាម
- លើកកម្ពស់ការបញ្ជ្រាបការយល់ដឹងវិស័យបរិស្ថាន និងការអភិវឌ្ឍដោយចីរភាពទៅក្នុងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធ-សាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងពាក់ព័ន្ធ
- ពង្រឹងនិងពង្រីកការអនុវត្តគោលនយោបាយ «ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព» ជាមួយនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សហការ និងកៀរគរការគាំទ្រ ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន សំដៅសម្រេចបាននូវភាពជោគជ័យនៃយុទ្ធសាស្ត្រ ភាពស្អាត ភាពបៃតង និងចីរភាព។

### អាទិភាពទី២ ៖ ការពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍

- ដឹកនាំការចរចា និងសម្របសម្រួល ការអនុវត្តគោលនយោបាយ លិខិតបទដ្ឋានគតិយុត្តផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងនានា ពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងការអភិវឌ្ឍដោយចីរភាព

- ដឹកនាំការចរចា និងសម្របសម្រួលការងារបច្ចេកទេសពាក់ព័ន្ធនឹងសេដ្ឋកិច្ចបៃតង ការប្រែប្រួលអាកាសធាតុ ការអភិរក្សជីវៈចម្រុះ និងជីវ-សុវត្ថិភាព
- ដឹកនាំ ការសម្របសម្រួល និងចូលរួមក្នុងវេទិកា សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងព្រឹត្តិការណ៍នានាពាក់ព័ន្ធក្នុងក្របខណ្ឌអង្គការសហ-ប្រជាជាតិ
- ផ្សព្វផ្សាយ និងចែករំលែកនូវបទពិសោធន៍ល្អៗនិងភាពជោគជ័យសំខាន់ៗ ដែលក្រសួងសម្រេចបាន ជូនដល់ដៃគូអភិវឌ្ឍន៍បានយល់ដឹងប្រតិបត្តិតាម និងបន្តការគាំទ្រ សំដៅលើកកិត្យានុភាពរបស់ក្រសួងក្នុងសហគមន៍អន្តរជាតិ
- បញ្ជ្រាបការងារបរិស្ថាន និងការអភិវឌ្ឍដោយចីរភាពទៅក្នុងគោល-នយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងពាក់ព័ន្ធ
- សម្រួចកម្មវិធី និងគម្រោងនានាក្នុងវិស័យបរិស្ថាន និងការអភិវឌ្ឍដោយចីរភាព ដើម្បីឆ្លើយតបទៅនឹងទិសដៅអាទិភាពរបស់ក្រសួងបរិស្ថាន
- សហការ និងកៀរគរការគាំទ្រ ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ សំដៅសម្រេចបានភាពជោគជ័យនៃយុទ្ធសាស្ត្រភាពស្អាត ភាពបៃតង និងចីរភាពឈានឆ្ពោះទៅសម្រេចការអភិវឌ្ឍប្រកបដោយអព្យាក្រឹតកាបូន។

## អាទិភាពទី៣ ៖ លើកទឹកចិត្តការចូលរួមនៃវិស័យឯកជន និងសាធារណជន

- បំផុសស្មារតីសាធារណជន ឱ្យយល់យល់ដឹងអំពីផលប៉ះពាល់អវិជ្ជមាននៃការបំផ្លាញបរិស្ថាន ដើម្បីចូលរួមក្នុងសកម្មភាពមេត្រីបរិស្ថាន

-ផ្សព្វផ្សាយនិងអប់រំសាធារណជន ឱ្យយល់ដឹងអំពីអត្ថប្រយោជន៍នៃការការពារបរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព

-ពង្រីកចលនាសាធារណជនឱ្យចូលរួមកាន់តែសកម្ម ក្នុងកិច្ចការងារនៃវិស័យបរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព

-បង្កើតទម្លាប់ល្អដល់សាធារណជន ឱ្យទទួលយកនិងចូលរួមប្រតិបត្តិយុទ្ធសាស្ត្រ ភាពស្អាត និងភាពបៃតង និងចីរភាពដែលបានដាក់ចេញដោយក្រសួងបរិស្ថាន

-លើកទឹកចិត្តវិស័យឯកជន ឱ្យចូលរួមសកម្មភាពជាមួយក្រសួង តាមរយៈការផ្តល់ជូនបណ្ណថ្លែងអំណរគុណ បណ្ណសរសើរ និងការអញ្ជើញឱ្យចូលរួមក្នុងព្រឹត្តិការណ៍បរិស្ថាននានា

-កសាងសមត្ថភាពវិស័យឯកជន ជាពិសេស ស្ថាប័នហិរញ្ញវត្ថុឯកជនឱ្យក្លាយជា «អង្គភាពទទួលស្គាល់ Accredited Entity» ដើម្បីទទួលបានប្រាក់កម្ចីមានអត្រាការប្រាក់ទាបពី មូលនិធិអាកាសធាតុបៃតង មូលនិធិបន្សុាំនឹងការប្រែប្រួលអាកាសធាតុ និងមូលនិធិដទៃទៀត

-សហការ និងកៀរគរការគាំទ្រ ដើម្បីលើកកម្ពស់ការចូលរួមរបស់វិស័យឯកជន និងសាធារណជនសំដៅសម្រេចឱ្យបាននូវភាពជោគជ័យនៃយុទ្ធសាស្ត្រ ភាពស្អាត ភាពបៃតង និងចីរភាព។

## មុំទី៣ ការពង្រឹងការសម្របសម្រួល

### អាទិភាពទី១ ៖ ការលើកកម្ពស់ការអនុវត្តកិច្ចការងារនៃក្រុមការងារពាក់ព័ន្ធ

-ធ្វើបច្ចុប្បន្នភាពក្រុមការងារអន្តរក្រសួង ក្រុមការងារបច្ចេកទេស និងមន្ត្រីបង្គោលពាក់ព័ន្ធនឹងការងារបរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព

-សម្របសម្រួលការងារគ្រប់គ្រង និងការងារបច្ចេកទេសជាមួយនឹងក្រសួង-ស្ថាប័ន អង្គភាពពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងដៃគូអភិវឌ្ឍន៍នានា ដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងការអនុវត្តការងារសំដៅសម្រេចគោលដៅនៃយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន

-រៀបចំកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល សិក្ខាសាលា និងព្រឹត្តិការណ៍នានា ដើម្បីធ្វើបច្ចុប្បន្នភាពការងារ ពង្រីកមិត្តភាព និងពង្រឹងសមត្ថភាពដល់ក្រុមការងារពាក់ព័ន្ធ

-តាមដានការអនុវត្តការងាររបស់ក្រុមការងារពាក់ព័ន្ធ និងផ្តល់អនុសាសន៍ដើម្បីតម្រង់ទិសការអនុវត្តការងារបន្តឱ្យកាន់តែមានប្រសិទ្ធភាព

-សម្របសម្រួល និងកៀរគរការគាំទ្រ ដើម្បីលើកកម្ពស់ការអនុវត្តរបស់ក្រុមការងារពាក់ព័ន្ធនៅក្នុងវិស័យបរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព។

## អាទិភាពទី២ ៖ ការសម្រួចការរៀបចំកម្មវិធីនិងគម្រោងពាក់ព័ន្ធ

-បង្កើតគណៈកម្មាធិការគ្រប់គ្រងកម្មវិធីនិងគម្រោង ដើម្បីតម្រង់ទិសនៃការអនុវត្តគម្រោងនានាឱ្យបំពេញគ្នាទៅវិញទៅមក និងស្របតាមទិសដៅអាទិភាពរបស់ក្រសួងដែលមានពកម្រិត គឺ រដ្ឋលេខាធិការស្ថិតនៅក្នុងឋានានុក្រមជាអ្នកដឹកនាំ អនុរដ្ឋលេខាធិការជាអ្នកសម្របសម្រួល និងមន្ត្រីថ្នាក់អគ្គនាយក ចុះក្រោមជាអ្នកគ្រប់គ្រងនិងអនុវត្តគម្រោង

-ធ្វើបច្ចុប្បន្នភាពកម្មវិធីនិងគម្រោងដែលកំពុងអនុវត្ត ដើម្បីពិនិត្យ និងតម្រង់ទិសអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាព

-សិក្សាស្វែងយល់ពីគំរូនៃឧត្តមានុវត្តពីបណ្តាប្រទេសនានា និងពីស្ថានភាពជាក់លាក់នៃប្រទេសកម្ពុជា ដើម្បីរៀបចំនិងគ្រប់គ្រងកម្មវិធីនិងគម្រោងឱ្យបានល្អប្រសើរ

- សម្របសម្រួល និងកៀរគរការគាំទ្រដើម្បីសម្រួចការរៀបចំនិងការអនុវត្តកម្មវិធី និងគម្រោងពាក់ព័ន្ធក្នុងវិស័យបរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព។

**អាទិភាពទី៣ ៖ ការពង្រឹងការតាមដាន និការវាយតម្លៃកម្មវិធីនិងគម្រោងពាក់ព័ន្ធ**

- ពង្រឹងអង្គភាពគ្រប់គ្រងកម្មវិធីនិងគម្រោងនីមួយៗដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តឱ្យស្របតាមទិសដៅអាទិភាពរបស់ក្រសួង
- ធ្វើបច្ចុប្បន្នភាពជាទៀងទាត់ អំពីលទ្ធផលនៃការអនុវត្តកម្មវិធីនិងគម្រោងនានាក្នុងវិស័យបរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព
- តាមដាន វាយតម្លៃ និងផ្តល់អនុសាសន៍ដល់ការអនុវត្តកម្មវិធីនិងគម្រោងនានា ឱ្យកាន់តែមានប្រសិទ្ធភាព
- សម្របសម្រួល និងកៀរគរការគាំទ្រ ដើម្បីពង្រឹងការតាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីនិងគម្រោងពាក់ព័ន្ធនៅក្នុងវិស័យបរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព។

## ៥. យន្តការអនុវត្ត

**យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន (២០២៣-២០២៨)** ត្រូវបានរៀបចំឡើងដើម្បីតម្រង់ទិស និងចង្អុលបង្ហាញអាទិភាពការងាររបស់ក្រសួង ក្នុងការលើកកម្ពស់កិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយចីរភាព ដោយមានយុទ្ធសាស្ត្រស្នូល និងយុទ្ធសាស្ត្រចំនួនបីផ្សេងទៀត គឺ «ភាពស្អាត» «ភាពបៃតង» និង «ចីរភាព» សម្រាប់ប្រតិបត្តិ និងប្រែក្លាយសក្តានុពលវិស័យបរិស្ថាន ឱ្យក្លាយជាផលប្រយោជន៍ពិតជាក់ស្តែង

បម្រើដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់ជំនាន់ និងសម្រាប់ចូលរួមក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសកល។

ដោយហេតុថា បរិស្ថានគឺជាសសរស្តម្ភមួយ ក្នុងចំណោមសសរស្តម្ភផ្សេងទៀត រួមមាន សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលត្រូវមានតុល្យភាពក្នុងការគាំទ្រគ្នាទៅវិញទៅមក សម្រាប់ការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព ដូច្នេះ ការអនុវត្តយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថានឱ្យទទួលបានជោគជ័យ គឺត្រូវមានយន្តការអនុវត្តប្រកបដោយសមត្ថភាព ការចូលរួម និងសាមគ្គីភាព ក្នុងការធ្វើអនុលោមភាព កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលការងារ ដើម្បីបំពេញតួនាទីនិងភារកិច្ចរៀងខ្លួន ឱ្យមានប្រសិទ្ធភាពនិងប្រសិទ្ធផលខ្ពស់ សំដៅសម្រេចបាននូវគោលដៅនិងផលប្រយោជន៍រួម។ យន្តការអនុវត្តទាំងនោះ រួមមានយន្តការអន្តរក្រសួង យន្តការក្រសួង និងយន្តការថ្នាក់ក្រោមជាតិ។

## ៥.១. យន្តការអន្តរក្រសួង

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) បានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៥ ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព សំដៅធានាបាននូវតុល្យភាពរវាង សេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌ ក្នុងព្រះរាជាណាចក្រកម្ពុជា។ សមាសភាពរបស់ ក.ជ.អ.ច. មាន នាយករដ្ឋមន្ត្រីជាប្រធានកិត្តិយស រដ្ឋមន្ត្រីក្រសួងបរិស្ថានជាប្រធាន និងមានរដ្ឋលេខាធិការ អគ្គលេខាធិការនៃស្ថាប័នពាក់ព័ន្ធ ចំនួន៣៥រូបទៀត ជាអនុប្រធាន និងសមាជិក។

ក.ជ.អ.ច. ជាយន្តការអន្តរក្រសួង មានបេសកកម្មក្នុងការរៀបចំនិងវាយតម្លៃគោលនយោបាយ យុទ្ធសាស្ត្រ ការកៀរគរធនធាន ការកសាងសមត្ថភាព

និងការពង្រឹងកិច្ចសហប្រតិបត្តិការ ពាក់ព័ន្ធនឹងការអភិវឌ្ឍប្រកបដោយចីរភាព ដែលគ្របដណ្តប់លើការគ្រប់គ្រងធនធានធម្មជាតិ។ ក.ជ.អ.ច. មានតួនាទី និងភារកិច្ចស្នូល ដូចខាងក្រោម ៖

- រៀបចំណែនាំ សម្របសម្រួលការអនុវត្ត និងការវាយតម្លៃគោល-នយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោង ពាក់ព័ន្ធនឹងការអភិវឌ្ឍប្រកបដោយចីរភាព
- កៀរគរការគាំទ្រ និងធនធាន សម្រាប់ការអនុវត្តគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងនានា
- ជំរុញ និងលើកកម្ពស់ការសិក្សាស្រាវជ្រាវ ការអប់រំ ការបណ្តុះបណ្តាល ការផ្លាស់ប្តូរបច្ចេកវិទ្យា និងការផ្សព្វផ្សាយ
- កសាងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន គ្រឹះស្ថានសិក្សាស្រាវជ្រាវ និងអ្នកពាក់ព័ន្ធផ្សេងទៀត
- ដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការងារសេដ្ឋកិច្ចបៃតង ការប្រែប្រួលអាកាសធាតុ ការអភិរក្សជីវៈចម្រុះនិងជីវសុវត្ថិភាព។

ក្រៅពី ក.ជ.អ.ច. យន្តការអន្តរក្រសួងនៅមានក្រុមការងារបច្ចេកទេសជាច្រើនទៀត ដែលបានបង្កើតឡើងដោយមានសមាសភាពមកពីអង្គភាពជំនាញនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ដើម្បីសម្របសម្រួលការរៀបចំផែនការ ការអនុវត្តការងារ និងការតាមដាននិងវាយតម្លៃការងាររបស់អង្គភាពជំនាញ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងវិស័យបរិស្ថាន និងការអភិវឌ្ឍប្រកប

ដោយចីរភាព។ ក្រុមការងារបច្ចេកទេស មានតួនាទីនិងភារកិច្ចពាក់ព័ន្ធនឹងការសម្របសម្រួល ដូចខាងក្រោម ៖

- សម្របសម្រួលក្នុងការងារគ្រប់គ្រង និងបច្ចេកទេសជាមួយអង្គភាពជំនាញ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ដើម្បីរួមគ្នាសម្រេចគោលដៅរួមក្នុងវិស័យបរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព
- សម្របសម្រួលក្នុងការរៀបចំកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល សិក្ខាសាលា និងព្រឹត្តិការណ៍នានា ដើម្បីធ្វើបច្ចុប្បន្នភាពការងារ ពង្រីកមិត្តភាព និងពង្រឹងសមត្ថភាពដល់ក្រុមការងារពាក់ព័ន្ធ
- សម្របសម្រួលក្នុងការតាមដានអនុវត្តការងាររបស់សមាជិក នៃក្រុមការងារ ដើម្បីផ្តល់ជាអនុសាសន៍ សម្រាប់តម្រង់ទិសនិងពង្រឹងការអនុវត្តការងារបន្ត។

## ៥.២. យន្តការក្រសួង

យោងអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ក្រសួងបរិស្ថានមានបេសកកម្មដឹកនាំនិងគ្រប់គ្រងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាពការរស់នៅប្រកបដោយចីរភាព សម្រាប់ជាឧត្តមប្រយោជន៍យូរអង្វែងរបស់ប្រជាជនគ្រប់រូបនិងគ្រប់ជំនាន់។ ក្រសួងមានសេនាធិការផ្ទាល់ចំនួនប្រាំគឺ **អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានគាំពារបរិស្ថាន អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន** និង**អគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន។** ក្រសួងបរិស្ថាន ជាសេនាធិការរបស់រាជរដ្ឋាភិបាល មានតួនាទីនិងភារកិច្ចពាក់ព័ន្ធនឹងយន្តការអន្តរក្រសួង រួមមាន ៖

–រៀបចំទស្សនវិស័យ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ព្រមទាំងកំណត់អាទិភាពក្នុងវិស័យបរិស្ថាន ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងដៃគូអភិវឌ្ឍន៍

–តាក់តែង និងអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព

–សម្របសម្រួលជាមួយនឹងក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ ផែនការ និងកម្មវិធីនានាពាក់ព័ន្ធ

–គ្រប់គ្រងនិងសម្របសម្រួលគ្រប់កិច្ចការងារពាក់ព័ន្ធ កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ការអភិវឌ្ឍសហគមន៍មូលដ្ឋាន ជាមួយនឹងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍នានា និងវិស័យឯកជន។

## ៥.៣. យន្តការថ្នាក់ក្រោមជាតិ

យោងតាមតួនាទី និងភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងក្របខណ្ឌគណនេយ្យភាពខ្សែទទឹង រដ្ឋបាលខេត្តមានតួនាទីជាអ្នកគាំទ្រការអនុវត្តគោល-នយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងគម្រោងនានាដែលពាក់ព័ន្ធនឹងធនធានធម្មជាតិក្នុងខេត្តសាមី ដែលមានមន្ទីរបរិស្ថានខេត្តជាសេនាធិការលើផ្នែកគ្រប់គ្រងនិងរដ្ឋបាល និងជាសេនាធិការរបស់ក្រសួងបរិស្ថានលើផ្នែកបច្ចេកទេស។

រីឯរដ្ឋបាលស្រុក-ក្រុង និងរដ្ឋបាលឃុំ-សង្កាត់ មានតួនាទីជាអ្នកសហការនិងចូលរួមជាមួយនឹងមន្ទីរបរិស្ថាន ក្នុងការអនុវត្តគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព គោលការណ៍ណែនាំកម្មវិធីនិងគម្រោងពាក់ព័ន្ធឱ្យមានប្រសិទ្ធភាព។

ផ្អែកតាមប្រកាស ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់មន្ទីរបរិស្ថាន មន្ទីរបរិស្ថានមានតួនាទី និងភារកិច្ចពាក់ព័ន្ធនឹងយន្តការថ្នាក់ក្រោមជាតិ ដូចខាងក្រោម ៖

- ដឹកនាំការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យបរិស្ថាន
- ដឹកនាំការគ្រប់គ្រងនិងការទប់ស្កាត់បទល្មើសធនធានធម្មជាតិ ការ-អភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍសហគមន៍មូលដ្ឋាន
- ផ្ដល់ការលើកទឹកចិត្តដល់សហគមន៍មូលដ្ឋាន តាមរយៈការគាំទ្រហេដ្ឋា-រចនាសម្ព័ន្ធសេដ្ឋកិច្ចមូលដ្ឋាន ការផ្សព្វផ្សាយ ការអប់រំបរិស្ថាន និងការល្បាតព្រៃរួមជាដើម សំដៅបង្កើតការងារបៃតង និងប្រាក់ចំណូលបន្ថែមជូនដល់ប្រជាសហគមន៍
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន ប្រជាពលរដ្ឋមូលដ្ឋាន និងអ្នកពាក់ព័ន្ធផ្សេងទៀត។

## ៦. សន្និដ្ឋាន

នយោបាយឈ្នះឈ្នះនៃ**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានធ្វើឱ្យប្រទេសកម្ពុជាទទួលបាននូវសុខសន្តិភាព ឯកភាពជាតិ និងឯកភាពទឹកដីទាំងស្រុងក្នុងរយៈពេលជាង២៥ឆ្នាំចុងក្រោយនេះ។ ប្រការនេះបានបង្កលក្ខណៈគ្រប់គ្រាន់ និងជាកាលានុវត្តភាពរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តនូវយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំង៤ដំណាក់កាល ប្រកបដោយជោគជ័យ និងប្រសិទ្ធភាពជាមួយសមិទ្ធផលជាច្រើនលើគ្រប់វិស័យ ទាំងនយោបាយ សង្គម និងសេដ្ឋកិច្ច ដែលធ្វើឱ្យប្រទេសកម្ពុជាទទួលបាន កិត្តិយសកេរ្តិ៍ឈ្មោះ និងការទទួលស្គាល់នៅលើឆាកអន្តរជាតិ។

ឈរលើមូលដ្ឋាននៃសមិទ្ធផល ដែលរាជរដ្ឋាភិបាលសម្រេចបានខាងលើ វិស័យបរិស្ថានត្រូវបានបន្តចាត់ជាទិសដៅអាទិភាពក្នុង **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល** នីតិកាលទី៧នៃរដ្ឋសភា សម្រាប់ការកសាងនិងការការពារមាតុភូមិ ឆ្នាំ២០២៣-២០២៨ និង **យុទ្ធសាស្ត្របញ្ចកោណ** ដំណាក់កាលទី១ ដើម្បី កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ក្រោមអាណត្តិដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។** ក្នុងបរិការណ៍នេះ ក្រសួងបរិស្ថានក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំ **យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន (២០២៣-២០២៨)** ជាផែនទីបង្ហាញផ្លូវ និងយន្តការអនុវត្តការងារក្នុងវិស័យបរិស្ថាន សម្រាប់រយៈពេល៥ឆ្នាំខាងមុខ។

**យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន** ត្រូវបានរៀបចំឡើងដើម្បីតម្រង់ទិសការអនុវត្តការងារក្នុងវិស័យបរិស្ថានដែលមាន **យុទ្ធសាស្ត្រស្នូល** មានមុំបី គឺ ការពង្រឹងគោលនយោបាយ ការកសាងរដ្ឋបាលឌីជីថល និងការពង្រីកការផ្សព្វផ្សាយ។ យុទ្ធសាស្ត្រស្នូល គឺជាកម្លាំងចលករដ៏សំខាន់ដើម្បីជំរុញនិងគាំទ្រចំពោះយុទ្ធសាស្ត្រចំនួនបីទៀត រួមមាន **យុទ្ធសាស្ត្រទី១ ភាពស្អាត យុទ្ធសាស្ត្រទី២ ភាពបៃតង** និង **យុទ្ធសាស្ត្រទី៣ ចីរភាព**។ យុទ្ធសាស្ត្រចក្រា នឹងលើកកម្ពស់វិស័យបរិស្ថានកម្ពុជា ក្នុងរយៈពេល៥ឆ្នាំខាងមុខនេះ ឱ្យរឹតតែមានភាពរីកចម្រើន សំដៅធានាឱ្យបាននូវចីរភាពបរិស្ថាន និងសុក្រឹតកម្មបរិស្ថានកិច្ច ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងលើកកម្ពស់ដល់សេដ្ឋកិច្ចបៃតងឱ្យរឹតតែមានប្រសិទ្ធភាព សម្រាប់ជាឧត្តមប្រយោជន៍ចំពោះប្រជាពលរដ្ឋកម្ពុជាគ្រប់ជំនាន់ និងលើកតម្កើងកិត្យានុភាពប្រទេសកម្ពុជាក្នុងឆាកអន្តរជាតិ៕

# កំណត់ត្រា

# កំណត់ត្រា

# កំណត់ត្រា

# កំណត់ត្រា